**Declassified to Public**
**06 September 2012**

[០២/១០/២០០៧] [០០២/១៩-០៩-២០០៦]

ជូនចំពោះអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងក្ដីព្រហ្មទណ្ឌ៖ | ០០២/១៩-០៩-២០០៦ |
| សំណុំរឿងឈ្មោះ៖ | កាំងហ្គិចអៀវ |
| | ហៅ ឌុច |
| ពាក្យបណ្ដឹងដាក់ទៅ៖ | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ពាក្យបណ្ដឹង៖ | ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ |
| ភាគីដាក់ពាក្យបណ្ដឹង៖ | លោក Jeffrey M. KAHAN |
| | ក្នុងឋានៈជាអ្នកជូនយោបល់ដល់តុលាការ |
| ភាសាដើម៖ | អង់គ្លេស |
| ប្រភេទនៃឯកសារ៖ | រក្សាការសម្ងាត់ |

---

*សារណា* របស់អ្នកដែលមិនមែនភាគីនៃរឿងក្ដី
ទាក់ទងទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន
ចេញនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

---

ពាក្យបណ្ដឹងដាក់ដោយ៖ លោក Jeffrey M. KAHAN

# I. សេចក្តីផ្តើម

១. ដោយមានការគោរពដ៏ខ្ពង់ខ្ពស់ចំពោះតួនាទីជាប្រវត្តិសាស្ត្រ និងយ៉ាងសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អវតក) ដែលកំពុងដំណើរការទៅមុខ និងអាស្រ័យទៅតាមការអញ្ជើញនៃការជូនដំណឹងជាសាធារណៈនៅថ្ងៃទី៤ ខែកញ្ញា របស់ប្រធាននៃអង្គបុរេជំនុំជម្រះ ដែលអនុលោមទៅតាមវិធាន៣៣ នៃវិធានផ្ទៃក្នុង ខ្ញុំ Jeffrey M. KAHAN(*"អ្នកជូនយោបល់ដល់តុលាការរបស់លោកអ្នក")* បានដាក់សារណានេះក្នុងនាមជាអ្នកជូនយោបល់តុលាការ។ ការអញ្ជើញនេះបានអនុញ្ញាតឲ្យមានការប្រគល់សារណាទាំងឡាយក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងជាសាធារណៈ។[1]

២. តាមរយៈសារតាសង្ខេប *អ្នកជូនយោបល់ដល់តុលាការរបស់លោកអ្នក* នេះជាមេធាវីមួយរូប និងជាសមាជិកដែលមានកិត្តនាមនៅក្នុងគណៈមេធាវីនៃរដ្ឋ New Jersey និងរដ្ឋ New York ក្នុងសហរដ្ឋអាមេរិក។ ចាប់តាំងពីខែសីហា ឆ្នាំ២០០៣មក *អ្នកជូនយោបល់ដល់តុលាការរបស់លោកអ្នក* ជាទីប្រឹក្សាផ្នែកច្បាប់ និងអភិវឌ្ឍន៍របស់អង្គការ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (Cambodian Defenders Project "CDP")។ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលមួយនៅកម្ពុជា ហើយជាអ្នកផ្តល់នូវសេវាជំនួយផ្នែកច្បាប់ដល់ជនទីក្រីក្រ និងងាយរងគ្រោះថ្នាក់ ដែលបានជួបប្រទះបញ្ហាផ្លូវច្បាប់ជាមួយតុលាការកម្ពុជា។ អង្គការនេះក៏មានផ្តល់នូវសេវាសំខាន់ដ៏ទៃទៀតផងដែរ ដូចជាការផ្តល់ចំណេះដឹងផ្លូវច្បាប់ ការបណ្តុះបណ្តាល និងជួយគាំទ្រដល់ការគោរពសិទ្ធិមនុស្ស និងការពង្រឹងនិងការអភិវឌ្ឍនីតិរដ្ឋនៅកម្ពុជា។ ជាពិសេសតាំងពីពេលបង្កើតមករហូតដល់ពេលបច្ចុប្បន្ន អ្នកគាំពារនិងមេធាវីរបស់ CDP បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតប្រព័ន្ធយុត្តិធម៌មួយដែលយល់ដឹងច្បាស់និងចាត់វិធានការការពារនិងពង្រឹងការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេសពាក់ព័ន្ធទៅនឹងការអនុវត្តត្រឹមត្រូវតាមនីតិវិធីច្បាប់ និងសិទ្ធិទទួលការកាត់ទោសដោយត្រឹមត្រូវ។

៣. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានកកើតមកហើយៗកំពុងប្រតិបត្តិការនេះមានតួនាទីដ៏សំខាន់និងជា ប្រវត្តិសាស្ត្រ និងត្រូវទទួលខុសត្រូវក្នុងការផ្តល់យុត្តិធម៌ទៅដល់មនុស្សរាប់

[1] http://www.eccc.gov.kh/english/cabinet/press/38/Pre-trial_statement_4_Sept_07_ENG.pd

លាននាក់ដែលបានស្លាប់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងមនុស្សរាប់លាននាក់ដែលមិនបានរាប់ឈ្មោះ ដែលកំពុងតែរស់នៅជាមួយមរតកបន្សល់ទុកឲ្យយ៉ាងអមនុស្សធម៌។

៤. ភារកិច្ចស្នូលរបស់ អវតក គឺផ្តល់យុត្តិធម៌ ប្រកបដោយសមត្ថភាព ឯករាជ្យភាព និងអនាគតិភាព នៅក្រោមគោលការណ៍នីតិរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា។

៥. ដូច្នេះ បំណងតែមួយគត់របស់*អ្នកជូនយោបល់ដល់តុលាការ* គឺត្រូវបំពេញតួនាទីខ្លះ ទោះជាធំ ឬតូចក៏ដោយ ដើម្បីជួយ អវតក ក្នុងការផ្តល់យុត្តិធម៌ ក្នុងលក្ខណៈមួយដែលស្របទៅនឹងក្រឹតក្រម និងដែនកំណត់របស់ច្បាប់ដូចដែលបានចែងនិងអនុញ្ញាតឲ្យ និងត្រូវគោរពដោយពេញលេញនូវសិទ្ធិមនុស្សជាមូលដ្ឋានដែលបានទទួលការការពារដូចមានចែងក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ជាពិសេសកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR) ហើយដែលតុលាការជាតិនិង អវតក ត្រូវតែលើកម្ពស់និងអនុវត្តតាមគោលការណ៍និងបទប្បញ្ញត្តិទាំងអស់ដែលបានរៀបរាប់មកនេះ។

៦. សារណានៃ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*នេះនឹងផ្តោតដោយផ្ទាល់ទៅលើការទទួលខុសត្រូវផ្នែកតុលាការ និងជាពិសេសដំណោះស្រាយរបស់អវតក ចំពោះបញ្ហាដ៏សំខាន់ក្រៃលែងនៃរឿងក្តីកាំងហ្គិចអៀវ ហៅឌុច(“ឌុច”) អតីតជាមេគុកសន្តិសុខ ស.២១ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩។

## II. សាវតានៃនីតិវិធី

៧. ឌុចបានត្រូវចោទប្រកាន់ កាត់ទោសនិងឃុំខ្លួនដោយតុលាការយោធានៃព្រះរាជាណាចក្រកម្ពុជា នៅខែឧសភា ឆ្នាំ១៩៩៩ ដោយផ្អែកលើក្រឹត្យច្បាប់លេខ២ ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់។[2]

៨. នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ ឌុចបានត្រូវទទួលការចោទប្រកាន់បន្ថែម និងត្រូវបានឃុំខ្លួនក្នុងតុលាការយោធាអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយអនុលោមទៅតាមក្រឹត្យច្បាប់លេខ១។[3]

[2] អាន "ដីកាបញ្ជូនរឿងក្តីឲ្យស៊ើបសួរ" ចេញដោយព្រះរាជអាជ្ញាយោធានៅថ្ងៃ១០ ឧសភា ១៩៩៩។

[3] អាន "ដីកាបញ្ជូនរឿងក្តីឲ្យស៊ើបសួរ" ចេញដោយព្រះរាជអាជ្ញាយោធានៅថ្ងៃ៦ កញ្ញា ១៩៩៩។

៩. មកដល់ខែសីហា ឆ្នាំ២០០១ ច្បាប់ដំបូងក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មប្រព្រឹត្តឡើងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់អវតក I") បានចូលជាធរមាន។

១០. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ នៅពេលកំពុងជាប់ឃុំមុនពេលជំនុំជម្រះ តាំងពីឆ្នាំ១៩៩៩ មក ក្រោមបទចោទនៃក្រិត្យច្បាប់លេខ១ និងលេខ២ ឌុចបានត្រូវចោទប្រកាន់ដោយដាក់លាក់ ហើយតុលាការយោធាបានចេញដីកាបង្គាប់ឲ្យឃុំខ្លួន ឌុច នៅក្រោម ច្បាប់ស្តីពីការបង្កើត អវតក មាត្រា៥ ដែលចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[4]

១១. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៣ តុលាការយោធាបានបន្តការឃុំខ្លួន ឌុច បណ្តោះអាសន្ន ដោយចោទអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[5]

១២. នៅខែមិថុនា ឆ្នាំ២០០៣ ការចរចាររវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានចប់សព្វគ្រប់។ កិច្ចព្រមព្រៀង ("កិច្ចព្រមព្រៀង") ទាក់ទងនឹងការបង្កើត និងការប្រតិបត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានត្រូវសម្រេច ហើយបានក្លាយទៅជាច្បាប់ នៅខែតុលា ឆ្នាំ ២០០៤។

១៣. នៅ ខែតុលា ឆ្នាំ២០០៤ ច្បាប់អវតក I បានត្រូវធ្វើវិសោធនកម្មដើម្បីសម្របទាំងស្រុងទៅនឹងកិច្ចព្រមព្រៀង។ ក្រោយពេលធ្វើវិសោធនកម្ម កំណែថ្មីចុងក្រោយនៃច្បាប់អវតកត្រូវចូលជាធរមានដោយយោងទៅលើច្បាប់អវតកត្រង់មានមាត្រាណាដែលការធ្វើវិសោធនកម្មមិនមានប៉ះពាល់ទៅលើបទប្បញ្ញត្តិរបស់ច្បាប់ អវតក I នោះទេ។

១៤. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៤ តុលាការយោធាបានបន្តឃុំខ្លួន ឌុច មុនពេលជំនុំជម្រះ ដោយចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្រោមច្បាប់អវតក។[6]

១៥. នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ តុលាការយោធាបានចោទប្រកាន់ និងចេញដីកាដាក់លាក់ឃុំខ្លួន ឌុច ដោយចោទពីបទរំលោភបំពានលើច្បាប់អវតក មាត្រា៦ ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម និងមាត្រា ៨ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលការការពារជាអន្តរជាតិ។[7]

---

[4] អាន ដីកាឃុំខ្លួនចេញដោយចៅក្រមស៊ើបអង្កេតនៃតុលាការយោធា នៅថ្ងៃ២២ កុម្ភៈ ២០០២។
[5] អាន ដីកាឃុំខ្លួនចេញដោយចៅក្រមស៊ើបអង្កេតនៃតុលាការយោធា នៅថ្ងៃ២២ កុម្ភៈ ២០០៣។
[6] អាន ដីកាឃុំខ្លួនចេញដោយចៅក្រមស៊ើបអង្កេតនៃតុលាការយោធា នៅថ្ងៃ២២ កុម្ភៈ ២០០៤។
[7] អាន ដីកាឃុំខ្លួនចេញដោយចៅក្រមស៊ើបអង្កេតនៃតុលាការយោធា នៅថ្ងៃ២៨ កុម្ភៈ ២០០៥។

១៦. នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ តុលាការយោធាបានពន្យាការឃុំខ្លួន ឌុច មុនពេលជំនុំជម្រះ ដោយផ្អែកទៅលើតាមមាត្រា ៦ និង ៨ នៃច្បាប់អវតក។

១៧. ប្រហែលនៅក្នុងខែកក្កដា ឆ្នាំ២០០៦ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និង ចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាកំពូលរបស់ អវតក បានធ្វើសច្ចាប្រណិធានជាផ្លូវការ។

១៨. ប្រហែលនៅក្នុងខែមិថុនា ឆ្នាំ២០០៧ វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាបានត្រូវអនុម័ត។

១៩. នៅខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញានៅ អវតក បានប្រគល់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរទាក់ទងនឹងរូប ឌុច ទៅសហចៅក្រមស៊ើបអង្កេត ដោយចោទពីបទឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិក្រោមច្បាប់ អវតក ត្រង់មាត្រា៥។

២០. នៅក្នុងករណីនេះ មានសំនួរសំខាន់ៗពីរ សម្រាប់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងបញ្ហា នេះ ដែលមានអត្ថន័យដូចតទៅ៖

១. ដោយមានការទទួលស្គាល់ និងយល់យ៉ាងច្បាស់អំពីបទចោទ និងដីកាឃុំខ្លួនឌុច ដែលរូប ឌុច បានត្រូវឃុំខ្លួនដោយតុលាការយោធាកម្ពុជា តាំងពីឆ្នាំ១៩៩៩ ហើយជាពិសេសចាប់តាំងពី ខែកុម្ភៈ ឆ្នាំ២០០២ ដោយអនុលោមទៅតាមច្បាប់អវតក មាត្រា៥ ចោទអំពីបទឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ដោយគ្មានសវនាការ តើសហចៅក្រមស៊ើបអង្កេតរបស់ អវតក ព្រមទទួលអនុវត្ត យុត្តាធិការទៅលើ ឌុច ដោយយោងទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលប្រគល់ដោយ សហព្រះរាជអាជ្ញា នៅក្រោមច្បាប់ អវតក មាត្រា៥ ដោយចោទអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

២. ដោយផ្អែកលើលទ្ធផលនៃបញ្ហាយុត្តាធិការ ដោះស្រាយបញ្ហាឃុំខ្លួនបណ្តោះអាសន្ន។

២១. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាឃុំខ្លួន បណ្តោះអាសន្ន ដែលមានអត្ថន័យថា ចៅក្រមបានបញ្ជាឲ្យ អវតក អនុវត្តយុត្តាធិការទៅលើរូបឌុច ដោយផ្អែកលើច្បាប់អវតក មាត្រា៥ អំពីបទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយឃុំរូបឌុច បណ្តោះអាសន្នក្នុងអំឡុងពេលមិនលើសពីមួយឆ្នាំ។[8]

[8] អានដីកាឲ្យឃុំខ្លួនបណ្តោះអាសន្នចេញដោយសហចៅក្រមស៊ើបអង្កេតនៃ អវតកនៅថ្ងៃ៣១ កក្កដា ២០០៧។

## III. សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី*

២២. បទដ្ឋានត្រឹមត្រូវដែលសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះនៃអវតក ត្រូវអនុវត្តក្នុងពេលដំណើរការធ្វើការសម្រេចចិត្ត និងចេញសាលក្រមឬសាលដីកា ("បទដ្ឋានអវតក")គឺត្រូវតែអាចយល់បាន និងបង្កើតជាលក្ខខណ្ឌចាំបាច់ជាមូលដ្ឋានគ្រឹះមួយ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ យកទៅធ្វើការវិភាគនិងធ្វើការសម្រេចចិត្តថាតើ អវតក គួរអនុវត្តយុត្តាធិការទៅលើរូប ឌុច ដែរឬអត់? បើអនុវត្ត គួរតែដោះស្រាយបញ្ហានៃការឃុំខ្លួនបណ្ដោះអាសន្ន។

២៣. នៅក្នុង"មូលដ្ឋានក្នុងការសម្រេចចិត្ត" ("មូលដ្ឋាន") ដោយគាំទ្រដល់ដីកាឃុំខ្លួនបណ្ដោះអាសន្ន("ដីកា") សហចៅក្រមស៊ើបអង្កេត ខកខានមិនបានអនុវត្តបទដ្ឋានដែលត្រឹមត្រូវរបស់ អវតក។ ក្នុងទស្សនទានច្បាប់ដើម្បីអនុវត្តតាមសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី គឺ ៖

- ជួយគាំទ្រការអនុវត្តត្រឹមត្រូវតាមបទដ្ឋានរបស់អវតក ដែលអង្គបុរេជំនុំជម្រះត្រូវធ្វើតាមពាក្យបណ្ដឹងឧទ្ធរណ៍នេះ។
- ក្នុងការអនុវត្តបទដ្ឋាននេះ អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី នឹងបង្ហាញថាមានមូលដ្ឋានពិតប្រាកដ និងគ្រប់គ្រាន់ក្នុងនីតិវិធី និងច្បាប់កម្ពុជា ដែលបញ្ជាក់យ៉ាងច្បាស់ថា សិទ្ធិរបស់ ឌុច បានត្រូវរំលោភបំពាន ដោយអត្តនោម័តនិងត្រឹមត្រូវ ដែលអាចចាត់ទុកថាធ្ងន់ធ្ងរ និងជាក់ស្ដែងណាស់។
- ម្យ៉ាងទៀត អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី នឹងបង្ហាញនៅក្រោមបទដ្ឋាន អវតក ថាមិនមានចម្លើយគ្រប់គ្រាន់ទេ នៅក្នុងនីតិវិធី និងច្បាប់កម្ពុជា សម្រាប់ដោះស្រាយបញ្ហាទាក់ទងទៅនឹងមធ្យោបាយតាមផ្លូវច្បាប់ឱ្យសមរម្យទាក់ទងនឹងការរំលោភបំពានសិទ្ធិរបស់ឌុច ហេតុដូចនេះហើយយោងទៅលើសភាពធ្ងន់ធ្ងរនៃបទចោទ និងភារកិច្ចជាប្រវត្តិសាស្ត្ររបស់ អវតក ដើម្បីឱ្យសមហេតុផល ត្រឹមត្រូវនិងសមរម្យ គួរស្វែងរកការណែនាំពីក្នុងវិធានដែលមានចែងក្នុងកម្រិតអន្តរជាតិ។
- ក្នុងការស្វែងរកការណែនាំនេះ អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីទទួលស្គាល់ថាមានអំណាចដែលគួរឱ្យជឿជាក់គាំទ្រនិងបញ្ជាក់អំពីសេចក្ដីសម្រេចចិត្ត និងសាលាក្រមរបស់អង្គបុរេជំនុំជម្រះដែលថាយុត្តាធិការរបស់អវតក មិនត្រូវអនុវត្តលើរូបឌុច ដូចមាននៅក្នុងទ្រឹស្ដីស្ដីពីការរំលោភលើកិច្ចដំណើរការនីតិវិធីដែលបានបង្កើតឡើងក្នុងច្បាប់អន្តរជាតិ។

- អ្នកដែលមិនមែនជាភាគីនៃរឿងក្តី នឹងទុកទឡ្ហីករណ៍សំខាន់ៗដទៃទៀត ទោះជាទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការផ្តល់ឧបាស្រ័យចំពោះការរំលោភបំពានសិទ្ធិ ឲ្យមេធាវីការពារក្តីខុច ឬ អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដទៃទៀត។

## IV. ផ្នែកច្បាប់

**ក តាសារដែលពាយយល់ក្នុងវិធានផ្ទៃក្នុង ក្នុងកិច្ចព្រមព្រៀង និងច្បាប់របស់អវតក បានបង្កើតជាបទដ្ឋានចាំបាច់ សម្រាប់ប្រតិបត្តិតាម ដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ក្នុងពេលធ្វើការសម្រេចចិត្ត និងសេចក្តីវិនិច្ឆ័យ។**

២៤. សហចៅក្រមស៊ើបអង្កេត (អាចហៅថា "ចៅក្រម") និងអង្គជំនុំជម្រះដ៏ទៃទៀត រួមមានអង្គបុរេជំនុំជម្រះ (អាចហៅថា "អង្គជំនុំជម្រះ") នៅ អវតក ត្រូវអនុវត្តនូវបទដ្ឋាន អវតក ក្នុងពេលធ្វើការសម្រេចចិត្ត និងសេចក្តីវិនិច្ឆ័យ ដូចមាននៅក្នុងវិធានផ្ទៃក្នុង ("IRs") កិច្ចព្រមព្រៀង និងច្បាប់របស់អវតក។

២៥. ការបង្កើត និងការអនុវត្ត IRs ជាជំហានចាំបាច់ក្នុងដំណើរការអភិវឌ្ឍន៍របស់អវតក។ វិធានផ្ទៃក្នុង ផ្តល់នូវវិធាននៃនីតិវិធី និងបទដ្ឋានសំខាន់ៗ សម្រាប់សកម្មភាពផ្សេងៗរបស់ អវតក។ អ្នកធ្វើពង្រាងវិធានផ្ទៃក្នុង បានដឹងនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការប្រតិបត្តិតាមនូវកិច្ចព្រមព្រៀង និងច្បាប់អវតក ដែលទាក់ទងទៅនឹងតម្រូវការថាត្រូវអនុវត្តច្បាប់ និងនីតិវិធីកម្ពុជាចំពោះសកម្មភាពរបស់ អវតក ជាមួយនឹងជម្រើសស្វែងរកការណែនាំពីក្នុងវិធានទាំងឡាយដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ នៅពេលណាដែលមានតម្រូវការចាំបាច់ និងសំខាន់។

២៦. IR.២ គឺជាចំណុចដ៏សំខាន់ណាស់ក្នុងការស្វែងយល់ និងអនុវត្តនូវបទដ្ឋានត្រឹមត្រូវរបស់អវតក។ IR.២ បញ្ជាក់ថា៖

> វិធាន២ នីតិវិធីអនុវត្តសម្រាប់បញ្ហាចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង
>
> នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត

ឬអង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី ឬមាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ ហើយនិងច្បាប់នីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន។[9]

២៧. យោងទៅលើIR.២ IR.២ ទទួលស្គាល់ថាមានព្រំដែនកំណត់របស់ IRsចំពោះរាល់សំនួរ និងបញ្ហាទាំងឡាយនៅចំពោះមុខ អវតក។ ដូច្នេះ IR.២ បានបញ្ជាក់ច្បាស់ថា បើមានបញ្ហាដែលមិនបានដោះស្រាយដោយ IRs នោះការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធទៅនឹងបញ្ហានោះ ត្រូវអនុវត្តទៅតាមស្មារតីនៃកិច្ចព្រមព្រៀងកិច្ចព្រមព្រៀង និងច្បាប់អវតក ដោយផ្តោតទៅលើ“គោលការណ៍ដូចមានចែងក្នុងវិធាន២១ និងច្បាប់នីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន”។ កាលណាបញ្ហាដែលមិនមានចម្លើយក្នុង IR តាមខ្លឹមសារនៃកិច្ចព្រមព្រៀង និងច្បាប់អវតក បានបញ្ជាក់ច្បាស់ថា អវតក ត្រូវពិនិត្យមើល និងអនុវត្តជាបឋមទៅតាមច្បាប់ និងនីតិវិធីកម្ពុជា ចំពោះសំណួរនិងបញ្ហាណាមួយដែលត្រូវនាំយកមកចំពោះមុខ អវតក។

២៨. មាត្រា ១២ នៃកិច្ចព្រមព្រៀង មិនអាចច្បាស់ជាងនេះទេលើចំណុចនេះ

> ១. នីតិវិធីរបស់អវតក ត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរក ការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។[10]

២៩. មាត្រា ២៣ នៃច្បាប់អវតក បញ្ជាក់នូវរបៀបដែលសហចៅក្រមស៊ើបអង្កេតត្រូវគ្រប់គ្រង និងសម្រេចលើបញ្ហានៅចំពោះមុខពួកគាត់។ ដោយស្របទៅនឹងវាក្យស័ព្ទរបស់មាត្រា ១២ នៃកិច្ចព្រមព្រៀង មាត្រា ២៣ និយាយបញ្ជាក់ថា:

> រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា សហចៅក្រមស៊ើបអង្កេត ដោយអនុវត្តតាមនីតិវិធីដែល

---

[9] វិធានផ្ទៃក្នុងទី២។

[10] កិច្ចព្រមព្រៀង មាត្រា១២(១)។

នៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋានដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។[11]

៣០. កិច្ចព្រមព្រៀង និងច្បាប់អវតក បានចែងយ៉ាងច្បាស់ថា នៅពេលដែលច្បាប់ និងនីតិវិធីកម្ពុជា នៅក្នុងរយៈពេលដំបូងប៉ុណ្ណោះ មិនបានរកដំណោះស្រាយសម្រាប់បញ្ហាណាមួយ ការណែនាំនឹងជាជម្រើសមួយ ហើយមិនមែនជាតម្រូវការទេ នឹងត្រូវស្វែងរក នៅក្នុងវិធាន និងបទដ្ឋាន ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

## ខ បទដ្ឋានដែលត្រឹមត្រូវ និងនៅជាធរមានរបស់អវតក

៣១. អានឲ្យបានដិតដល់និងប្រុងប្រយ័ត្នលើដីកាបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេត មិនបានបង្កើត និងអនុវត្តឲ្យបានត្រឹមត្រូវនូវបទដ្ឋានរបស់អវតក ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ។

៣២. បញ្ហាពិសេសអំពីយុត្តាធិការបានកើតឡើងយ៉ាងច្បាស់នៅចំពោះមុខចៅក្រម ហើយឥឡូវនេះទៀតនៅចំពោះមុខអង្គជំនុំជម្រះមុន គឺថាតើមានអំណាចយុត្តាធិការឬក៏អត់លើរូប ឌុច ដោយផ្អែកលើសារតានីតិវិធីរបស់ ឌុច ដែលបានត្រូវឃុំខ្លួនដោយតុលាការយោធាតាំងពីឆ្នាំ ១៩៩៩ ដោយចោទប្រកាន់អំពីបទចោទមួយចំនួយដែលមិនជាប់ទាក់ទងទៅនឹងយុត្តាធិការរបស់អវតក ហើយការឃុំខ្លួនអស់រយៈពេល ៥ឆ្នាំកន្លះ ចាប់តាំងពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០២ គឺដោយផ្អែកទៅលើច្បាប់អវតក មាត្រា៥ អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការឃុំខ្លួនទាំងអស់នេះ មិនដែលបាននាំខ្លួនគាត់ មកកាត់សេចក្ដីនៅចំពោះមុខតុលាការទាល់តែសោះ។

៣៣. ដោយអនុលោមទៅតាម IR.២ សហចៅក្រមស៊ើបអង្កេត ជាបឋមត្រូវដោះស្រាយបញ្ហាយុត្តាធិការ ដោយអនុវត្តស្របទៅតាមខ្លឹមសាររបស់ IRs ប្រសិនមានចែង។

[11] ច្បាប់ អវតក មាត្រា ២៣។

៣៤. ដោយមានការគោរពដ៏ខ្ពង់ខ្ពស់ដល់សហចៅក្រមស៊ើបអង្កេត យើងឃើញថាជំហានទីមួយចាំបាច់ មិនបានប្រតិបត្តិតាមទេ។ ចៅក្រមមិនបានខិតខំពិនិត្យមើលលើមូលដ្ឋានរបស់ខ្លួន ថាតើបញ្ហានោះមាននិយាយឬទេ នៅក្នុង IRs ។

៣៥. ការពិនិត្យទាំងស្រុង និងយ៉ាងប្រុងប្រយ័ត្ននៃ IRs បង្ហាញថាបញ្ហាយុត្តាធិការពិសេស តាមការពិតទាក់ទងនឹងបញ្ហានេះមិនមានចែងទេ។ ប៉ុន្តែបើមានវិញក៏ធ្វើក្នុងលក្ខណៈដែលខ្វះភាពពិតប្រាកដ និងអំណាចច្បាស់លាស់ ដែលចៅក្រមឬអង្គជំនុំជម្រះនេះអាចសម្រេចចិត្ត និង កាត់សេចក្ដីដោយត្រឹមត្រូវ និងពេញសមត្ថភាព។

៣៦. និយាយម្យ៉ាងទៀត IRs មិនបានផ្ដល់នូវបទដ្ឋាន និងសមត្ថកិច្ចនីតិវិធីច្បាស់លាស់ ទៅដល់ចៅក្រម និងអង្គជំនុំជម្រះ គឺថាតើមានអំណាចយុត្តាធិការឬក៏អត់លើរូប ឌុច ដោយផ្អែកលើសាវតានីតិវិធីរបស់ ឌុច ដែលបានត្រូវឃុំខ្លួនដោយតុលាការយោធាតាំងពីឆ្នាំ ១៩៩៩ ដោយចោទប្រកាន់អំពីបទចោទមួយចំនួយដែលមិនជាប់ទាក់ទងទៅនឹងយុត្តាធិការរបស់អវតក ហើយការឃុំខ្លួនអស់រយៈពេល ៥ឆ្នាំកន្លះ ចាប់តាំងពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០២ គឺដោយផ្អែកទៅលើច្បាប់ អវតក មាត្រា៥ អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការឃុំខ្លួនទាំងអស់នេះ មិនដែលបាននាំខ្លួន គាត់ មកកាត់សេចក្ដីនៅចំពោះមុខតុលាការទាល់តែសោះ។

៣៧. ដូច្នេះ ដោយអនុលោមទៅតាមបទដ្ឋានរបស់អវតក គឺតម្រូវការឲ្យចៅក្រម "ធ្វើសេចក្ដីសម្រេចចិត្ត ដោយយោងទៅតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី ឬ ៣៧ថ្មីនៃច្បាប់អវតកដែលចូលជាធរមាន ដោយមានការប្រុងប្រយ័ត្នជាពិសេសទៅលើគោលការណ៍គ្រឹះ ដែលចែងក្នុងវិធាន ២១ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន"។[12]

៣៨. មាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២៣ នៃ ច្បាប់អវតក បានត្រូវដកស្រង់ទាំងស្រុងដាក់ក្នុងកថាខណ្ឌ ២៨ និង២៩ខាងលើ។

៣៩. ដោយអនុលោមទៅតាមបទដ្ឋានរបស់អវតក គឺតម្រូវចាំបាច់ឲ្យចៅក្រមពិនិត្យជាបឋមលើច្បាប់ និងនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន អំពីបញ្ហាយុត្តាធិការនេះ។

៤០. ជាថ្មីម្ដងទៀតដោយក្ដីគោរព ខ្ញុំសូមបង្ហាញថា ចៅក្រមមិនបានធ្វើដូចនេះទេ។ ចៅក្រមមិនខិតខំពិនិត្យមើលច្បាប់ និងនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន ដែលទាក់ទងនឹងបញ្ហាយុត្តាធិការ។

---

[12] វិធានផ្ទៃក្នុងទី២។

ប្រសិនបើមិនអនុវត្តតាមបទដ្ឋានរបស់អវតក នៅពេលធ្វើការសម្រេចចិត្តលើបញ្ហានេះ ចៅក្រមត្រូវពិនិត្យមើលដោយផ្ទាល់ទៅលើយុត្តិសាស្ត្ររបស់តុលាការជាតិអំពីបញ្ហាយុត្តាធិការស្តីពីគោលការណ៍ *ការចាប់ខុស ប៉ុន្តែមិនខុសនីតិវិធីយុត្តាធិការតុលាការក្នុងការឃុំខ្លួនស្របច្បាប់ (male captus, bene detendus)* និងការរំលោភបំពានលើកិច្ចដំណើរការនីតិវិធី។

៤១. ដោយយល់និងការអនុវត្តិន៍នូវបទដ្ឋានអវតក អង្គជំនុំជម្រះត្រូវចងចាំថារចនាសម្ព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ន ជារចនាសម្ព័ន្ធមួយផ្អែកទៅលើច្បាប់រដ្ឋប្បវេណី (Civil Law)។ អ្នកជំនាញច្បាប់ម្នាក់ឈ្មោះ Antonin Scalia ដែលមានសមត្ថកិច្ចមិនតិចជាងប្រព័ន្ធយុត្តិធម៌តុលាការកំពូលនៃសហរដ្ឋអាមេរិក បានចង្អុលចំណុចសំខាន់មួយថាក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី អំណាចពិតប្រាកដ គឺស្ថិតនៅក្នុងអត្ថបទច្បាប់ (text of the law) ហើយមតិយោបល់ផ្នែកច្បាប់ទាំងឡាយគ្រាន់តែ ត្រូវបានពិគ្រោះជាយោបល់ដើម្បីប្រសិទ្ធិភាពគួរឱ្យជឿទុកចិត្តបានប៉ុណ្ណោះ។[13]

៤២. ដូច្នេះ ចៅក្រមដំណោះស្រាយបញ្ហាជាបន្ទាន់ ដោយអនុវត្តនូវមតិយោបល់ច្បាប់ និងបានបំពានគោលការណ៍គ្រឹះជាមូលដ្ឋាននៃប្រព័ន្ធច្បាប់រដ្ឋប្បវេណី។

៤៣. បទដ្ឋានរបស់អវតក បានបញ្ជាក់យ៉ាងច្បាស់លាស់ថាការស្វែងរកការណែនាំពីវិធានដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ (ដែលអាចបញ្ចូលដោយស្របច្បាប់នូវយុត្តិសាស្ត្រមួយចំនួនតាមការយល់ឃើញរបស់ចៅក្រម) គឺគ្រាន់តែជានីតិវិធីបន្ទាប់បន្សំ និងជាជម្រើសប៉ុណ្ណោះ ដែលផ្ទុយពីនីតិវិធីជាបឋម និងអណ្ណត្តិរបស់ អវតតក។ ការណែនាំពីវិធានក្នុងកម្រិតអន្តរជាតិ ផ្តល់ជាជំនួយដ៏សំខាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងសេចក្តីវិនិច្ឆ័យ និងអាចយកជាការបាន ប៉ុន្តែមិនអាចពឹងផ្អែកទាំងស្រុងបាននោះទេគឺអាស្រ័យទៅលើការទាញយកវាមកប្រើប្រាស់ពីក្របខណ្ឌមួយដែលត្រឹមត្រូវសម្រាប់ការពិនិត្យមើលរបស់តុលាការនិងធ្វើការសម្រេចចិត្ត។

៤៤. ចៅក្រមដែលមិនបានយកចិត្តទុកដាក់ក្នុងការបង្កើត និងអនុវត្តបទដ្ឋានរបស់អវតកត្រូវតែកែតម្រូវនៅពេលមានពាក្យបណ្តឹងឧទ្ធរណ៍នេះ ដែលនេះគឺជាកំហុសផ្នែកច្បាប់ ។ បើអង្គជំនុំជម្រះឧកខានមិនបានកែប្រែដីកានេះទេ នោះបញ្ជាក់ថា ការអនុវត្តបទដ្ឋានត្រឹមត្រូវរបស់អវតក ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការវិនិច្ឆ័យស្របទៅតាមបទដ្ឋានរបៀបនេះទេ នឹងបង្កើតឱ្យមានកំហុសឆ្គង

---

[13] Antonin Scalia, តុលាការនៃCommon Law ក្នុងប្រព័ន្ធច្បាប់Civil Law"៖ តួនាទីរបស់តុលាការសហព័ន្ធនៃសហរដ្ឋអាមេរិកក្នុងការបកស្រាយ ច្បាប់ និងធម្មនុញ្ញ សាកលវិទ្យាល័យPrinceton ថ្ងៃ៨ ៩ មិនា ១៩៩៥។

ដែលមិនធ្លាប់មានពីមុនមក និងបង្កើតឲ្យបញ្ហាធ្ងន់ធ្ងរ និងមិនចាំបាច់ចោទមានឡើងចំពោះ សមត្ថភាព ឯករាជ្យភាព និងអនាគតិរបស់អវតក ក្នុងការផ្តល់យុត្តិធម៌ ។

**គ. ការអនុវត្តបទដ្ឋានរបស់អវតក**

៤៥. ដូចបានបញ្ជាក់ខាងលើ ចៅក្រមបានខកខានមិនបានអនុវត្តជាបឋមទៅតាម IR.២ ដែលតម្រូវឲ្យចៅក្រម ពិនិត្យមើល IRs ដើម្បីកំណត់ថាតើ IRs មានចែងអំពីបញ្ហាយុត្តាធិការលើសំណុំរឿង ឌុច ដែរឬទេ។ លើសពីនេះទៅទៀត ដូចបានបញ្ជាក់ខាងលើ ប្រសិនបើចៅក្រមបានអនុវត្តដោយត្រឹមត្រូវនូវជំហានបឋមដែលបានតម្រូវនោះ នឹងមានការបង្ហាញឲ្យឃើញថា IRs មិនបានផ្តល់នូវបទដ្ឋាននិងសមត្ថកិច្ចនីតិវិធីច្បាស់លាស់ទៅដល់ចៅក្រមនិងអង្គជំនុំជម្រះ
គឺថាតើមានអំណាច យុត្តាធិការឬក៏អត់លើរូប ឌុច ដោយផ្អែកលើសាវតានីតិវិធីរបស់ ឌុច ដែលបានត្រូវឃុំខ្លួនដោយតុលាការយោធាតាំងពីឆ្នាំ ១៩៩៩ ដោយចោទប្រកាន់អំពីបទចោទមួយចំនួយដែលមិនជាប់ទាក់ទងទៅនឹងយុត្តាធិការរបស់អវតក ហើយការឃុំខ្លួនអស់រយៈពេល ៥ឆ្នាំកន្លះ ចាប់តាំងពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០២ គឺដោយផ្អែកទៅលើច្បាប់អវតក មាត្រា៥ អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការឃុំខ្លួន ទាំងអស់នេះ មិនដែលបាននាំខ្លួន គាត់មកកាត់សេចក្តីនៅចំពោះមុខតុលាការទាល់តែសោះ។

៤៦. ដូច្នេះ ដើម្បីកំណត់អំពីបញ្ហាយុត្តាធិការ IR.២ តម្រូវឲ្យមានការអនុវត្តនូវមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ ២៣ ៣៣ ឬ៣៧ នៃច្បាប់ អវតក ដែលបានធ្វើវិសោធនកម្ម "ដោយធ្វើការប្រុងប្រយ័ត្នជាពិសេសទៅលើគោលការណ៍គ្រឹះដូចមានចែងក្នុងវិធាន ២១ និងច្បាប់នីតិ វិធីព្រហ្មទណ្ឌជាធរមាន"។

**គ(១). អវតក ជាតុលាការមួយ នៅក្នុងរចនាសម្ព័ន្ធតុលាការ កម្ពុជាបច្ចុប្បន្ន**

៤៧. ដើម្បីចាប់ផ្តើមពិនិត្យលើប្រធានបទដែលជាចំណុចស្នូលជាមូលដ្ឋាននេះ គឺត្រូវតែបញ្ជាក់ឲ្យច្បាស់ថា អវតក ជាតុលាការ នៅក្នុងរចនាសម្ព័ន្ធតុលាការបច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជា។ មាត្រា២នៃច្បាប់អវតកដែលបានធ្វើវិសោធនកម្ម មិនអាចបញ្ជាក់ឲ្យច្បាស់ជាងនេះទៀតទេលើចំណុចនេះ

អង្គជំនុំជម្រះវិសាមញ្ញត្រូវបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺ សាលាដំបូង និងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មរំលោភទៅលើច្បាប់មនុស្ស ធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ (ហើយដែលបានប្រព្រឹត្តក្នុងកំឡុងពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ៦ មករា ១៩៧៩។ (មានការបញ្ជាក់ជាបន្ថែម)។[14]

៤៨. ដើម្បីឲ្យច្បាស់ អវតក ជាតុលាការពិសេសមួយ ហៅថា "តុលាការកូនកាត់"។ តុលាការនេះជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមសម្រាប់វិនិច្ឆ័យបញ្ហាធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលមានបុគ្គលិកភាគច្រើនជាសញ្ជាតិខ្មែរ ដោយសហប្រតិបត្តិការ និងការសម្របសម្រួល ជាមួយអ្នកតំណាងមកពីសហគមន៍អន្តរជាតិនៅក្រោមសមត្ថកិច្ច និងជំនួយរបស់អង្គការសហប្រជាជាតិ។ ទោះបីជា អវតក ត្រូវបានទាំងអស់គ្នាទទួលស្គាល់ថាជាតុលាការដែលមានយុត្តាធិការ គោលបំណងនិងរចនាសម្ព័ន្ធរដ្ឋបាល ពិសេសជាប្រវត្តិសាស្ត្រយ៉ាងណាក៏ដោយ ប៉ុន្តែបើផ្អែកទៅលើខ្លឹមសារនៃច្បាប់អវតកដែលបានធ្វើវិសោធនកម្មបញ្ជាក់ថាអវតក គឺជាអង្គជំនុំជម្រះមួយដោយឡែក ឬជាអង្គជំនុំជម្រះជាន់ដំបូងដូចគ្នានឹងតុលាការខេត្តក្រុងដទៃទៀត និងតុលាការយោធាដែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូចគ្នានេះដែរ អវតក គឺជាអង្គជំនុំជម្រះពិសេសនៅក្នុងតុលាការកំពូលដែលមានស្រាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤៩. តាមខ្លឹមសារច្បាប់និងកិច្ចព្រមព្រៀងបានបញ្ជាក់យ៉ាងច្បាស់ថានៅពេលអវតកដោះស្រាយបញ្ហាណាមួយនៅចំពោះមុខ ត្រូវអនុវត្តច្បាប់និងនីតិវិធីជាធរមានរបស់កម្ពុជាជាអាទិភាពមុនច្បាប់ដទៃទៀត។ ។

៥០. ការពាក់ព័ន្ធរបស់សហចៅក្រមស៊ើបអង្កេតនៃអវតកលើរឿងក្ដីរបស់ឌុចគឺជាការអនុវត្តនីតិវិធីរបស់តុលាការជាន់ដំបូងនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដូចគ្នានឹងតុលាការយោធា និងចៅក្រមស៊ើបអង្កេតរបស់តុលាការយោធាដែលជាតុលាការសាលាដំបូងក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ដែលធ្វើការលើរឿងក្ដីរបស់ ឌុច ដែរ។

[14] ច្បាប់ អវតក កែប្រែ មាត្រា ២។

៥១. ដូច្នេះហើយ ដើម្បីឆ្លើយទៅនឹងសំនួរយុត្តាធិការនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែមានការយល់ដឹងអំពីយន្តការទាំងឡាយ នៅក្រោមច្បាប់នីតិវិធីកម្ពុជាជាធរមានដែលគ្រប់គ្រងលើបញ្ហាថាតើអវតកដែលក្នុងឋានៈដូចគ្នានឹងតុលាការជាន់ដំបូងរបស់តុលាការកម្ពុជាដោះស្រាយលើករណីរឿងក្តីខុច យ៉ាងដូចម្តេចដោយទៅលើប្រវត្តិនៃនីតិវិធីដែលមាននៅតុលាការយោធាដែលតាមការពិតជាតុលាការជាន់ដំបូងមួយដែរដែលមាននៅក្នុងរចាសម្ព័ន្ធតុលាការកម្ពុជា។

៥២. អង្គជំនុំជម្រះអាចរកឃើញយ៉ាងស្រួលក្នុងប្រព័ន្ធច្បាប់កម្ពុជា ពីទីកន្លែងរបស់តុលាការយោធាក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់។ ច្បាប់ក្រិត្យលេខ៦ ច្បាប់ស្តីពីការរៀបចំ និងសកម្មភាពនៃតុលាការកាត់ក្តីរបស់រដ្ឋកម្ពុជា (“ច្បាប់ស្តីពីតុលាការជំនុំជម្រះក្តី (Adjudicate Courts Laws”) និងបទប្បញ្ញត្តិទាក់ទងទៅនឹងនីតិវិធី និងច្បាប់ព្រហ្មទណ្ឌ និងតុលាការ ក្នុងសម័យកាលអន្តរកាល (“ច្បាប់ព្រហ្មទណ្ឌអន្តរកាល”) បង្ហាញដោយលម្អិតនូវគោលបំណង និងយុត្តាធិការរបស់តុលាការ យោធា ក៏ដូចជាកិច្ចព្រមព្រៀង និងច្បាប់អវតក ដែលបានចែងអំពី អវតក។

៥៣. ច្បាប់ស្តីពីតុលាការជំនុំជម្រះក្តី បង្ហាញថាតុលាការយោធាជាតុលាការថ្នាក់ក្រោមនៃសាលាដំបូង មានទីតាំងនៅភ្នំពេញ មានយុត្តាធិការលើដែនដីកម្ពុជាទាំងមូល។

មាត្រា ៩ នៃច្បាប់ស្តីពីតុលាការជំនុំជម្រះក្តីបានចែងថា:

> តុលាការយោធា ត្រូវមានសមត្ថកិច្ចក្នុងការកាត់សេចក្តី និងអាចបណ្តឹងឧទ្ធរណ៍បាន ចំពោះរឿងក្តីដែលទាក់ទងនឹងបទល្មើសផ្នែកយោធាទាំងឡាយ។
>
> បទល្មើសយោធាគឺជាបទល្មើសដែលបានប្រព្រឹត្តឡើងដោយសមាជិកយោធានៅក្នុងជួរកងទ័ព និងដែលមានការទាក់ទងទៅនឹងវិន័យកងទ័ព ឬទ្រព្យសម្បត្តិរបស់កងទ័ព។
>
> ក្នុងករណីដែលទាហានម្នាក់បានប្រព្រឹត្តបទល្មើសធម្មតា ជនប្រព្រឹត្តបទល្មើសនោះនឹងត្រូវកាត់សេចក្តីដោយតុលាការខេត្ត ក្រុង។
>
> នីតិវិធីនៃតុលាការយោធាត្រូវតែមានលក្ខណៈដូចគ្នានឹងតុលាការខេត្ត ក្រុង។[15]

៥៤. ការពិនិត្យមើលដោយមិនលំអៀងលើបញ្ហានោះចង្អុលបង្ហាញយ៉ាងច្បាស់ថា តុលាការយោធាមិនអាចមានយុត្តាធិការលើបុគ្គល ឬបទល្មើសដែលមានចែងក្នុងច្បាប់អវតកទេ ត្រង់មាត្រា៥ ការចោទប្រកាន់លើរូបខុចអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ចំណុចទីមួយ គឺជាកំហុសដែល

[15] ច្បាប់កាត់សេចក្តី មាត្រា៩។ បទប្បញ្ញត្តិទាក់ទិន នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មានខ្លឹមសារដូចគ្នាទៅនឹងច្បាប់កាត់សេចក្តី ដូច្នេះនឹងមិនមានឥទ្ធិពលទៅលើការធ្វើវិភាគនេះទេ។

តុលាការយោធាព្រម ទទួលចោទប្រកាន់លើរូបឌុចកាលពីពេលនោះ។ ឌុច អាចចាត់ទុកជាសមាជិកយោធាម្នាក់ដែលអាចស្ថិតនៅក្រោមក្របខ័ណ្ឌច្បាប់ស្ដីពីតុលាការជំនុំជម្រះក្ដី ។ ចំណុចទីពីរ ការបកស្រាយផ្នែកច្បាប់ណាមួយដែលមិនសមហេតុសមផលអះអាងថាបទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជា"បទល្មើសយោធា"ដែលអាចស្ថិតនៅក្រោមក្របខ័ណ្ឌច្បាប់ស្ដីពីតុលាការជំនុំជម្រះក្ដី។ ជាមូលដ្ឋាន ឧក្រិដ្ឋកម្មនេះ គឺជាបទឧក្រិដ្ឋមានកម្រិតខ្ពស់បំផុតនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ និងដូចដែលបាន ចែងនៅក្នុងច្បាប់ អវតក។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវនឹងអត្ថន័យនៃបទល្មើសពាក់ព័ន្ធនឹង "វិន័យយោធា ឬទ្រព្យសម្បត្តិរបស់កងទ័ព"ទេ។

៥៥. សំខាន់ជាងនេះទៅទៀត នៅពេលដែល ឌុច ត្រូវបានចោទប្រកាន់ នៅខែកុម្ភៈ២០០២ ដោយតុលាការយោធា នៅក្រោមមាត្រា ៥ នៃច្បាប់ អវតក I គឺកាន់តែបង្ហាញឲ្យឃើញច្បាស់លាស់ពិតប្រាកដចំពោះតុលាការយោធាថា អវតកត្រូវបានបង្កើតឡើងជាពិសេស និងដាក់លាក់ក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដែលមានសមត្ថកិច្ច ចោទប្រកាន់ទៅលើឌុច នៅក្រោមច្បាប់ អវតក។ ច្បាប់ស្ដីពីតុលាការជំនុំជម្រះក្ដីបានបញ្ជាក់យ៉ាងច្បាស់ថា បទល្មើសធម្មតាត្រូវតែកាត់ទោស នៅតុលាការខេត្ត ក្រុង។ ដូច្នេះ ជាការសមហេតុសមផលរាល់បទចោទទាំងឡាយដែលមានចែងក្នុងច្បាប់ អវតក ត្រូវតែមានការកាត់ទោសដោយ អវតក មិនមែនដោយតុលាការយោធាទេ។

៥៦. ថ្វីបើច្បាប់របស់អវតក មានគោលបំណងបង្កើតយន្តការឲ្យអវតកស្ថិតនៅក្នុងប្រព័ន្ធតុលាការជាតិកម្ពុជា ដើម្បីដោះស្រាយរាល់បញ្ហាទាំងឡាយ ដែលមានចែងក្នុងច្បាប់អវតក ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញានៃតុលាការយោធាកម្ពុជា បានសម្រេចធ្វើការនៅក្រោម និងសំអាងលើសមត្ថកិច្ចនៃច្បាប់អវតក ហើយទុកតុលាការយោធាជាតុលាការជាន់ដំបូង នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដើម្បីចាប់ផ្ដើមការចោទប្រកាន់ និងការស៊ើបអង្កេតតាមផ្លូវតុលាការលើករណី ឌុច នៅក្រោមមាត្រា ៥ អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**គ(២). ការរំលោភបំពានសិទ្ធិរបស់ ឌុច នៅក្រោមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសិទ្ធិជាមូលដ្ឋាននៃសិទ្ធិមនុស្ស នៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ**

៥៧. សិទ្ធិរបស់ ឌុច បានត្រូវរំលោភបំពាន និងប្រហែលជាមិនអាចជួសជុលបាន នៅក្រោមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

**គោលការណ៍ជាមូលដ្ឋានដែលបានបង្ហាញក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌ**

៥៨. ករណី ឌុច ដែលបានត្រូវចោទប្រកាន់ និងឃុំខ្លួន ដោយអនុលោមទៅតាមដីកាចេញដោយតុលាការយោធា នៅក្រោមច្បាប់អវតក បានចង្អុលយ៉ាងច្បាស់ទៅលើការរំលោភបំពានធ្ងន់ធ្ងរ លើច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា។

ដូចដែលបាននិយាយរួចមកហើយ ដោយអនុលោមទៅតាមច្បាប់ស្តីពីតុលាការជំនុំជម្រះក្តី តុលាការយោធាមានកាតព្វកិច្ច ប្រតិបត្តិតាមនីតិវិធីជាធរមានសម្រាប់តុលាការខេត្ត ក្រុង ដែលមាននៅពេលនោះ។

អ្វីដែលមានសារៈសំខាន់សម្រាប់ការវិភាគនេះគឺ ច្បាប់នីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលនៅជាធរមាននៅពេលដែល ឌុច បានត្រូវចោទប្រកាន់ និងឃុំខ្លួនក្នុងតុលាការយោធា ដោយចោទប្រកាន់នៅក្រោមច្បាប់ អវតកត្រង់មាត្រា៥ ។

៥៩. ច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្នចែងថាៈ

> ក្នុងគ្រប់កាលទោស រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវហួសពី បួនខែទេ។ ប៉ុន្តែដោយផ្អែកលើសុភនិច្ឆ័យត្រឹមត្រូវ រយៈពេលនេះអាចបន្តរហូតទៅដល់ ៦ខែ បើចាំបាច់សម្រាប់ការស៊ើបអង្កេត។ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសន្ធិសញ្ញាទាំងឡាយនៃអង្គការសហប្រជាជាតិ ដែលប្រទេសកម្ពុជាជាហត្ថលេខីមួយ ការឃុំខ្លួនបណ្តោះអាសន្នដូចចែងខាងលើអាចបន្តដល់មួយឆ្នាំ ប៉ុន្តែការបន្តនេះជាសរុប មិនត្រូវលើសពី ៣ឆ្នាំទេ។[16]

៦០. ច្បាប់ស្តីអំពីការឃុំខ្លួនបណ្តោះអាសន្ន បានកែប្រែក្នុងបទប្បញ្ញត្តិនៃ មាត្រា ១៤(៤) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ មាត្រា ១៤(៤) និយាយពីពេលវេលាកំណត់សម្រាប់ការឃុំខ្លួន មុនការជំនុំជម្រះចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែជាដាក់លាក់មិនមានបញ្ចូលបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ ទោះជាបានសន្មតជាមុន ក្នុងគោលបំណងវែកញែក ដែលថានៅខែកុម្ភៈ ២០០២ តុលាការយោធាបានអនុវត្តយ៉ាងត្រឹមត្រូវនូវយុត្តាធិការដោយចោទប្រកាន់ ហើយឃុំខ្លួន ឌុច អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ

---

[16] ច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន។

ក្រោមច្បាប់អវតក ហើយនៅចុងខែ កុម្ភៈ ២០០៥ តាមនីតិវិធីជាធរមានពិតប្រាកដ តុលាការយោធា មិនមានសិទ្ធិទៀតទេក្នុងការឃុំខ្លួន ឌុច អំពីបទចោទនោះ។

៦១. មិនត្រឹមតែតុលាការយោធាប៉ុណ្ណោះទេដែលមិនមានសិទ្ធិឃុំខ្លួន ឌុច អំពីបទចោទនោះ មាន ទឡ្ហីករណ៍គួរឲ្យចាប់អារម្មណ៍មួយ គឺនៅក្រោមនីតិវិធីកម្ពុជា នៅខែ កុម្ភៈ ២០០៥ ឌុច មានសិទ្ធិ ទទួលនូវ"ការជំនុំជម្រះ" អំពីបទចោទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មាត្រា ២១ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាលដែលនៅជាធរមាននៅពេលនោះ បានដាក់ពេលកំណត់ជាអតិបរិមាដែលតុលាការត្រូវកាត់ សេចក្តីជនណាម្នាក់អំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ មាត្រា២១(១)បញ្ជាក់ថា៖ "បុគ្គលគ្រប់រូប ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី *ត្រូវតែបានទទួលការកាត់ក្តី* យ៉ាងយូរបំផុតប្រាំមួយខែ ក្រោយពីថ្ងៃ ចាប់ខ្លួន"។[17] (មានបន្ថែមការបញ្ជាក់)

៦២. មាត្រា ២១(១) បាននិយាយពីបទល្មើសធម្មតា ដោយយោងទៅតាមមាត្រា ១៤(៤) នៃបទ បញ្ញត្តិ ស្តីពីការឃុំខ្លួនបណ្តោះអាសន្នមុនការកាត់សេចក្តី ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ នៅពេល ដែលមានការនិយាយពីច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្នទាក់ទងនឹងរយៈពេលអតិបរិមាក្នុងការ ឃុំខ្លួនបណ្តោះអាសន្នមុនការកាត់សេចក្តីចំពោះបទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ច្បាប់នេះមិន បាននិយាយថា"*ត្រូវតែបានទទួលការកាត់ក្តី*" ដូចគ្នាទៅនឹងមាត្រា២១(១)នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ទេ។

៦៣. យ៉ាងណាក៏ដោយ ក្នុងប្រព័ន្ធនីតិវិធីច្បាប់ដែលមាន ត្រូវតែបកស្រាយក្នុងលក្ខណៈគួរសម និង សមហេតុផល។ ជាការសមហេតុផល និងត្រឹមត្រូវក្នុងការប្រៀបធៀប ឧទាហរណ៍ថា បើជនជាប់ ចោទបានត្រូវចោទប្រកាន់អំពីបទល្មើសធម្មតាដូចជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ករណីមនុស្សឃាតគិតទុកជា មុន ត្រូវតែទទួលការវិនិច្ឆ័យទោសនៅពេលផុត រយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះ អាសន្ន រយៈពេល៦ខែហើយចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញជនជាប់ចោទនោះក៏ត្រូវតែទទួល ការ វិនិច្ឆ័យទោសផងដែរនៅពេលផុតរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នរយៈពេល3ឆ្នាំ។

៦៤. នៅក្នុងការវិភាគការអនុវត្តច្បាប់កម្ពុជា និងនីតិវិធីអំពីបញ្ញាយុត្តាធិការ តុលាការគួរតែ ពិចារណាផងដែរអំពីក្រមនីតិវិធីព្រហ្មទណ្ឌដែលទើបតែអនុម័ត នាពេលថ្មីៗនេះ។ ក្រមនីតិវិធី ព្រហ្មទណ្ឌ ("CPC") មិនបានចែងពីយុត្តាធិការ ការប្រព្រឹត្តទៅ ឬនីតិវិធីផ្សេងៗពាក់ព័ន្ធរវាង តុលាការ

[17] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា២១(១)។

យោធានិងតុលាការដទៃ ដូច្នេះនេះគឺជាចំណុចខ្វះចន្លោះនៃឲ្យច្បាប់ និងជាការត្រឹមត្រូវក្នុងការបន្ត អនុវត្តបទបញ្ញត្តិទាំងឡាយនៃច្បាប់ ស្តីពីតុលាការជំនុំជម្រះក្តី។ ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានបញ្ញត្តិស្រដៀងគ្នានេះដែរ ដែលបានចែងយ៉ាងច្បាស់ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងមាត្រាL. 413-26 មាត្រានេះបានចែងថា:

> ក្នុងបទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវឲ្យលើសពីរយៈពេល១ឆ្នាំទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែ នៅពេលដែលរយៈពេលនៃការឃុំខ្លួន បណ្តោះអាសន្ន ទាំងនេះត្រូវបានបញ្ចប់ចៅក្រមស៊ើបអង្កេតអាចពន្យាពេល (sic) ការឃុំខ្លួនបណ្តោះអាសន្ននេះ បានរយៈពេល ១ឆ្នាំបន្ថែមទៀត ដោយមានដីកាបញ្ជាក់ពីមូលហេតុត្រឹមត្រូវ ។ ការពន្យានេះអាចធ្វើទៅបានត្រឹមតែ២ដងប៉ុណ្ណោះ។ [18]

ជាថ្មីម្តងទៀត ក្នុងការអនុវត្តបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ នេះ ចំពោះការចោទប្រកាន់លើ ឌុច អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់តុលាការយោធា ឌុចអាចត្រូវឃុំខ្លួនបណ្តោះអាសន្នមុនពេលមានសវនាការ ក្នុងរយៈពេលតែ៣ឆ្នាំប៉ុណ្ណោះជាអតិបរមា។

៦៥. ផ្ទុយពីច្បាប់ព្រហ្មទណ្ឌអន្តរកាល ការពិនិត្យដោយម៉ត់ចត់ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានបញ្ជាក់ច្បាស់ថាដូចគ្នា ឬស្រដៀងគ្នាចំពោះពេលវេលាកំណត់ ដែលជនជាប់ចោទម្នាក់ “ត្រូវតែទទួលការកាត់សេចក្តីនោះទេ”។

៦៦. ដូច្នេះ ក្នុងការពិនិត្យឡើងវិញពីបញ្ហាយុត្តាធិការ (the jurisdiction matter) ដោយផ្តោតចំណាប់អារម្មណ៍ពិសេសចំពោះការអនុវត្តច្បាប់នីតិវិធីក្រមព្រហ្មទណ្ឌ យើងបានសង្កេតឃើញយ៉ាងច្បាស់នូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ឌុចជាបន្តបន្ទាប់។

៦៧. ជាដំបូងនេះគឺការអនុវត្តមិនត្រឹមត្រូវរបស់តុលាការយោធាចំពោះឌុច លើបញ្ហាបុគ្គលនិងផ្នែកយុត្តាធិការ យោងលើច្បាប់របស់ អវតក មាត្រា៥ អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដីកាឃុំខ្លួនលើកដំបូងរបស់ឌុច ទាក់ទងនឹងបទឧក្រិដ្ឋ កម្មប្រឆាំងមនុស្សជាតិ បានចេញនៅខែកុម្ភៈ ឆ្នាំ២០០២ ដូច្នេះមកទល់ពេលនេះ ឌុចត្រូវបានឃុំខ្លួន ក្រោមបទឧក្រិដ្ឋនៃច្បាប់ អវតក លើសពីរយៈពេល

[18] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា L. 413-26. ខ្លឹមសារមាត្រានេះមានន័យដូចនឹងវិធាន 63(6) និង(7) ដែលមានចែងក្នុងវិធានផ្ទៃក្នុង

៥ឆ្នាំកន្លះ ដោយមិនមានការវិនិច្ឆ័យទោសត្រឹមត្រូវណាមួយនោះទេ។ នេះបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ឌុច។

៦៨. ផ្អែកលើលក្ខន្តិកៈជាគោលការណ៍ នៅក្នុងច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី និងវិធានផ្ទៃក្នុង តំរូវឱ្យមានការឃុំខ្លួនបណ្តោះអាសន្នរយៈពេល៣ឆ្នាំ ដោយយោងលើស្ថានទំងន់ទោសជាក់ស្តែងនិងភាពស្មុគស្មាញនៃបទឧក្រិដ្ឋ រួមផ្សំនិងតំរូវការដែលតំរូវឱ្យមានការស៊ើបអង្កេតមួយដែលពេញលេញ និងពេញលក្ខណៈនៃបទឧក្រិដ្ឋប្រភេទនេះផងនោះ។ ក្នុងករណីនេះច្បាប់នីតិវិធីកម្ពុជាក៏បានបញ្ជាក់យ៉ាងមុតមាំថា បន្ទាប់ពីការឃុំខ្លួនដោយសមរម្យអស់រយៈពេល៣ឆ្នាំហើយ នោះត្រូវតំរូវឱ្យមានការកាត់សេចក្តីចំពោះឌុច។ ការប្រើភាសា"ត្រូវតែទទួលការកាត់សេចក្តី" នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល អាចបកប្រែដោយសមហេតុសមផលក្នុងន័យថា ឌុចគួរត្រូវបាននាំមកកាត់សេចក្តីជាមួយនឹង ដីកាចេញដោយតុលាការនៃសាលាដំបូង ដូច្នេះពេលនេះគាត់កំពុងត្រូវចោទប្រកាន់និងចាប់ខ្លួន ទាំងខុសឬត្រូវច្បាប់ ក្រោមច្បាប់ អវតក មាត្រា៥ ស្តីពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។

៦៩. តុលាការនៃសាលាដំបូងនេះគឺជាតុលាការយោធាកម្ពុជា ទាំងការចាប់ខ្លួននិងចោទប្រកាន់បានកើតឡើងនៅក្នុងតុលាការយោធារហូតមក។ ឥឡូវនេះ អវតក បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនហើយ ដោយមានចៅក្រមកាត់សេចក្តីជាច្រើនរូប និងមានសិទ្ធិត្រឹមត្រូវក្នុងការចាត់ចែងរឿងក្តីរបស់ឌុច។ ទោះជាយ៉ាងណាក៏ដោយ អង្គហេតុដែលតំរូវឱ្យ អវតក ចាត់ចែងរឿងក្តីរបស់ ឌុច នាពេលនេះ នឹងមិនត្រូវរំខានដោយបង្កាប់បញ្ហាផ្សេងៗ ដែលបណ្តាលឱ្យរកមិនឃើញ ឬមិនមានចែងឱ្យច្បាស់លាស់នៅក្នុងច្បាប់នីតិវិធីកម្ពុជាត្រូវរំងាប់ ឬទុកជាមោឃៈនូវរាល់ការរំលោភនានាដែល ឌុច បានទទួលរងក្រោមនីតិវិធីច្បាប់កម្ពុជាដែលទាំងតុលាការយោធា ក្រោមយុត្តាធិការច្បាប់ស្តីពីតុលាការជំនុំជម្រះក្តីនិងទាំងអវតក ក្រោមកិច្ចព្រមព្រៀង ច្បាប់អវតក និងវិធានផ្ទៃក្នុងដែលតុលាការ ទាំងពីរនេះ ត្រូវប្រតិបត្តិតាមនោះ។

## គោលការណ៍ជាសារវ័ន្តចែងក្នុងវិធាន២១

៧០. ផ្អែកតាមបទដ្ឋានរបស់អវតក គោលការណ៍ជាសារវ័ន្តមួយចំនួន ដែលបានចែង ក្នុងវិធាន២១ ក៏ត្រូវយកមកពិចារណានិងអនុវត្តផងដែរ។ វិធាន២១ ផ្តើមជាមួយនឹងតំរូវការជារួមថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់

ជាធរមាន ត្រូវតែបកស្រាយក្នុងន័យ *ការពារជានិច្ចដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ* ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង"[19] (បញ្ជាក់បន្ថែម)។

៧១. ដូច្នេះ យោងលើតម្រូវការដែលឲ្យមានការបកស្រាយច្បាប់ថា " ការពារជានិច្ចដល់ផលប្រយោជន៍"របស់ឌុចដែលជាជនត្រូវចោទនោះ វាពិតជាសមរម្យណាស់ក្នុងការវាយតំលៃបញ្ហាយុត្តាធិការក្រោមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលកំពុងអនុវត្តជាមួយនឹងកាលកំនត់ និងការយោគយល់ព្រមទាំងការគោរពសិទ្ធិនានាដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។ មាត្រា១៥០នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ដោយគ្មានមន្ទិលស្តីពីទីតាំងច្បាប់រដ្ឋធម្មនុញ្ញ នៅក្នុងឋានានុក្រមរបស់ច្បាប់កម្ពុជានានា: ច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់រដ្ឋ។[20] ដូច្នេះ ច្បាប់ទាំងអស់នៃប្រទេសកម្ពុជា រួមទាំងច្បាប់នីតិវិធីព្រហ្មទណ្ឌផងត្រូវតែតាក់តែងឡើង និងអនុវត្តដោយមិនមានប៉ះពាល់ដល់សិទ្ធិទាំងឡាយដែលធានានិងការពារដោយរដ្ឋធម្មនុញ្ញ។ សមត្ថកិច្ចនិងកម្មសិទ្ធិរបស់ច្បាប់និងវិធានទាំងអស់ គឺទាញចេញអំពីសិទ្ធិទាំងឡាយដែលការពារដោយរដ្ឋធម្មនុញ្ញ និងមិនអាចបំពានបាន។

៧២. ជាមួយគ្នានេះដែរ ការពិនិត្យអំពីសិទ្ធិមួយចំនួនដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញជាធរមានបង្ហាញឲ្យឃើញថា:

- មាត្រា៣២ ផ្តល់ការធានាថា "ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបត្រូវមានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងសុវត្ថិភាពផ្ទាល់ខ្លួន។"[21]
- មាត្រា៣៨ ផ្តល់ការធានាថា "ច្បាប់ត្រូវផ្តល់ការពារចំពោះជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ការចោទប្រកាន់ ការចាប់ខ្លួន ឬឃុំខ្លួនរបស់បុគ្គលណាម្នាក់ ត្រូវធ្វើបានវៀរលែងតែមានអំណះអំណាងផ្នែកច្បាប់ (...) ជនជាប់ចោទត្រូវចាត់ទុកថា

19 វិធានផ្ទៃក្នុង ២១

20 រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា ១៥០

21 រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា ៣២

គ្មានទោសរហូតដល់ពេលតុលាការកាត់សេចក្តីជាលើកចុងក្រោយ។

ប្រជាពលរដ្ឋគ្រប់ៗរូបមានសិទ្ធិគ្រប់គ្រាន់ក្នុងការការពារតាមរយៈបណ្តឹងឧបាស្រ័យ។"[22]

៧៣. ដូច្នេះ ក្រោមច្បាប់នីតិវិធីកម្ពុជាដែលទទួលសមត្ថកិច្ចពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមិនត្រូវរំលោភបំពានសិទ្ធិនានាដែលធានាក្រោមច្បាប់រដ្ឋធម្មនុញ្ញនោះ ឌុចមានបទពិសោធន៍ទទួលរងនូវការបំពានយ៉ាងធ្ងន់ធ្ងរពីសំណាក់តុលាការយោធា ទៅលើសិទ្ធិរបស់គាត់ដែលផ្តល់ដោយរដ្ឋធម្មនុញ្ញ ជាពិសេសគឺចំពោះច្បាប់ អវតក មាត្រា៥ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៤. តុលាការយោធាបានអនុវត្តចំពោះបញ្ហាបុគ្គលនិងផ្នែកយុត្តាធិការមិនបានត្រឹមត្រូវទេ ចំពោះច្បាប់របស់អវតក បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលបានចោទមកលើឌុច ហើយនឹងបានឃុំខ្លួនឌុចដោយយោងលើបទចោទនោះលើសពីរយៈពេលអតិបរមា៣ឆ្នាំនៃរយៈពេលឃុំខ្លួនបណ្តោះអាសន្នទៅទៀត។ ឥឡូវនេះ វាមានរយៈពេលលើសពី៥ឆ្នាំកន្លះហើយ តាំងពីពេលចេញដីកាឃុំខ្លួនលើកដំបូង ហើយឌុចនៅតែមិនទាន់បានទទួលនូវសវនាការដោយ យុត្តិធម៌មួយនៅឡើយទេចំពោះការចោទប្រកាន់នេះ។

៧៥. ការមើលឃើញ ការបកស្រាយ និងពាក្យសុំងាយយល់មួយទាក់ទងនឹងច្បាប់នីតិវិធីព្រហ្មទណ្ឌ និងសិទ្ធិនានាដែលបានចែងនិងធានាយ៉ាងរឹងមាំដោយរដ្ឋធម្មនុញ្ញនោះ បានបញ្ជាក់ថា:

- សិទ្ធិមានសេរីភាពនិងសុវត្ថិភាពផ្ទាល់ខ្លួនរបស់ឌុចត្រូវបានបំពាន
- សិទ្ធិទទួលការចោទប្រកាន់ ចាប់ខ្លួន និងឃុំខ្លួនតាមផ្លូវច្បាប់របស់ឌុចត្រូវបានបំពាន
- សិទ្ធិដែលត្រូវសន្មត់ជាមុនថាគ្មានទោសរបស់ឌុចត្រូវបានបំពាន
- សិទ្ធិទទួលការការពារតាមរយៈបណ្តឹងឧបាស្រ័យត្រូវបានបំពាន។

### គោលការណ៍ជាសារវន្តបានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

៧៦. ការអនុវត្តមាត្រា៣១នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ផ្តល់ឱកាសឲ្យយើងពង្រីកការវិភាគបន្ថែមទៀត ដើម្បីពិនិត្យនិងអនុវត្តសិទ្ធិមូលដ្ឋានសំខាន់ៗនៃនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ និងការកាត់សេចក្តីដោយយុត្តិធម៌ ដែលមានតាក់តែងផងដែរនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ មាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាចែងយ៉ាងច្បាស់ថា:

---

[22] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨

ព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់និងគោរពសិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កាតិកាសញ្ញា និង អនុសញ្ញានានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។[23]

មាត្រា៣១តំរូវឲ្យកម្ពុជាជាប់កាតព្វកិច្ចក្នុងការអនុវត្តសន្ធិសញ្ញាដោយមិនអាចជៀសបាន យោងលើការផ្តល់សច្ចាប័នរបស់ខ្លួនលើកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ "ICCPR" (The International Covenant on Civil and Political Rights)។

៧៧. ជាការពិតណាស់ដែល ICCPR គឺជាកាតិកាសញ្ញាមួយដែលទាក់ទងនឹងសិទ្ធិមនុស្ស។ ICCPR បានចែងនូវចំនុចពាក់ព័ន្ធនៅក្នុងផ្នែកមួយចំនួនដូចខាងគទៅនេះ:

**មាត្រា៩**

១. បុគ្គលគ្រប់ៗរូបមានសិទ្ធិមានសេរីភាពនិងសុវត្ថិភាពជាមនុស្ស។ គ្មានបុគ្គលណាមួយអាចត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តនោះទេ។ គ្មានបុគ្គលណាម្នាក់ អាចត្រូវគេដកហូតសិទ្ធិសេរីភាពរបស់ខ្លួនដោយគ្មានមូលហេតុនោះទេ ហើយប្រសិនបើមាន ការដកហូតសិទ្ធិសេរីភាពនោះ ការដកហូតត្រូវធ្វើឡើងតាមរយៈនីតិវិធីដែលមានចែងក្នុង ច្បាប់។

២. បុគ្គលណាមួយដែលត្រូវចាប់ខ្លួនត្រូវជូនជាដំណឹង នៅពេលដែលមានការចាប់ខ្លួន អំពីមូលហេតុផ្សេងៗនៃការចាប់ខ្លួនរបស់គាត់ និងត្រូវជូនជាដំណឹងជាបន្ទាន់នូវរាល់ការចោទ ប្រកាន់នានាចំពោះខ្លួនគាត់។

៣. បុគ្គលណាមួយដែលបានចាប់ខ្លួនឬឃុំខ្លួនពីបទល្មើសព្រហ្មទណ្ឌត្រូវនាំខ្លួនជា ប្រញាប់មកជួបចៅក្រម ឬមន្ត្រីផ្សេងទៀតដែលទទួលសិទ្ធិតាមផ្លូវច្បាប់ដើម្បីប្រតិបត្តិ អំណាចតុលាការ ហើយបុគ្គលនោះត្រូវទទួលការ កាត់សេចក្តីនៅក្នុងកំឡុងពេល ដ៏សមរម្យមួយ ឬត្រូវដោះលែង។ ជនទាំងឡាយណាដែលកំពុងរង់ចាំការកាត់សេចក្តី ត្រូវ ស្ថិតក្នុងការឃុំខ្លួន មិនត្រូវចាត់ជាវិធានទូទៅទេ ប៉ុន្តែការដោះលែងអាចធ្វើទៅបាន ដោយ មានការធានាថាជននោះនឹងបង្ហាញខ្លួននៅពេលសវនាការ នៅដំណាក់កាលផ្សេងទៀតនៃ

[23] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១

00154405



ដំណើរការកាត់សេចក្តី និងត្រូវមកបង្ហាញខ្លួនតាមពេលវេលាកំនត់សម្រាប់ការអនុវត្ត សាលក្រម។

៤. បុគ្គលណាមួយដែលត្រូវដកហូតសិទ្ធិសេរីភាពដោយការចាប់ខ្លួនឬឃុំខ្លួន ត្រូវមានសិទ្ធិទទួលការកាត់សេចក្តីនៅចំពោះមុខតុលាការ ដើម្បីឱ្យតុលាការអាចសំរេចដោយ មិនមានការពន្យាចំពោះការឃុំខ្លួនដោយស្របច្បាប់របស់គាត់ និងបញ្ជាឱ្យមានការដោះលែង ប្រសិនបើការឃុំខ្លួននោះធ្វើឡើងមិនត្រឹមត្រូវតាមច្បាប់។[24]

**មាត្រា១៤**

១. បុគ្គលគ្រប់ៗរូបមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការនិងសាលាក្តីនានា។ នៅក្នុងការកំនត់ពីបទចោទណាមួយទៅលើបុគ្គលនោះ ឬចំពោះសិទ្ធិរបស់បុគ្គល និងកាតព្វកិច្ចនៅក្នុងរឿងក្តីតាមផ្លូវច្បាប់ បុគ្គលគ្រប់ៗរូបមានសិទ្ធិទទួលបាននូវសវនាការជាសាធារណៈនិងមិនលំអៀង ដោយសាលាក្តីដែលអព្យាក្រិត្យ ឯករាជ្យ និងមានសមត្ថភាពដែលបង្កើតឡើងដោយច្បាប់ (...)

២. បុគ្គលគ្រប់ៗរូបដែលត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវទទួលបាននូវសិទ្ធិដែលត្រូវសន្មត់ជាមុនថាគ្មានទោសរហូតដល់ពេលដែលអាចបញ្ជាក់ថាមានពិរុទ្ធភាពតាមផ្លូវច្បាប់។

៣. នៅក្នុងការកំនត់ពីបទល្មើសព្រហ្មទណ្ឌណាមួយទៅលើបុគ្គលណាមួយនោះ បុគ្គលគ្រប់ៗ រូបមានសិទ្ធិទទួលបាននូវការធានាក្នុងកំរិតអប្បបរមាស្មើភាពគ្នា ដូចតទៅនេះ:

(a) ត្រូវទទួលបានការជូនដំណឹងជាបន្ទាន់ និងជាលំអិតក្នុងភាសាមួយដែលគាត់អាចយល់បានពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើគាត់

(b) ត្រូវមានពេលវេលានិងបរិក្ខារគ្រប់គ្រាន់សម្រាប់រៀបចំការការពារខ្លួន និងដើម្បីទំនាក់ទំនងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស

(c) ត្រូវទទួលបានការកាត់សេចក្តីដោយមិនមានការពន្យាពេល (...)[25]

៧៨. ស្របគ្នាជាមួយនឹងការវិភាគ និងពាក្យសុំខាងដើម នៃច្បាប់ នីតិវិធីព្រហ្មទណ្ឌកម្ពុជា និងសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ចំពោះករណីឌុច យើងសង្កេតឃើញថា មានការរំលោភ

---

[24] International Covenant on Civil and Political Rights, Article 9.
[25] International Covenant on Civil and Political Rights, Article 14

បំពានដដែលៗបានកើតឡើង នៅក្រោម ICCPR។ សិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាននៅក្រោម ICCPR មានដូចតទៅ:

- មាត្រា ៩(១) សិទ្ធិមានសេរីភាពនិងសុវត្ថិភាពផ្ទាល់ខ្លួន
- មាត្រា ៩(១) មានសិទ្ធិមិនឱ្យគេដកហូតសិទ្ធិសេរីភាពរបស់ខ្លួនដោយគ្មានមូលហេតុ ហើយប្រសិនបើមានការដកហូតសិទ្ធិសេរីភាពនោះ ការដកហូតត្រូវធ្វើឡើងតាមរយៈនីតិវិធី ដែលមានចែងក្នុងច្បាប់
- មាត្រា ៩(៣) សិទ្ធិឱ្យមានសវនាការ នៅក្នុងកំឡុងពេលសមរម្យមួយ ឬទទួលនូវការដោះលែង
- មាត្រា ១៤(១) សិទ្ធិទទួលបាននូវសវនាការជាសាធារណៈនិងមិនលំអៀង ដោយសាលាក្តីដែលអព្យាក្រិត្យ ឯករាជ្យ និងមានសមត្ថភាព ដែលបង្កើតឡើងដោយច្បាប់
- មាត្រា ១៤(២) ទទួលបាននូវសិទ្ធិដែលត្រូវសន្មត់ជាមុនថាគ្មានទោសរហូត ដល់ពេលដែលz អាចបញ្ជាក់ថាមានពិរុទ្ធភាពតាមផ្លូវច្បាប់។
- មាត្រា ១៤(៣) សិទ្ធិទទួលនូវការកាត់សេចក្តីដោយមិនមានការពន្យាពេល

៧៩. ពាក្យសុំប្រិតប្រៀងនិងត្រឹមត្រូវតាមបទដ្ឋានរបស់ អវតក បាននាំយើងឱ្យ មកដល់ចំនុចមួយដែលមិនអាចជៀសផុតពីការសន្និដ្ឋានមិនគួរសមមួយថា ក្រោមច្បាប់នីតិវិធីព្រហ្មទណ្ឌ និងសិទ្ធិមូលដ្ឋានដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិរបស់ឌុចត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ។

## គ(iii) ដំណោះស្រាយកែតំរូវដែលសមស្រប

៨០. ពេលនេះយើងត្រូវប្រឈមមុខជាមួយនឹងចំណោទដ៏ធំហើយលំបាកមួយ ដែលចាំបាច់ត្រូវឱ្យមានដំណោះស្រាយ: តើអ្វីទៅ ឬតើអ្វីដែលគួរជាការសំរេចដ៏សមស្របរបស់អង្គបុរេជំនុំ ជម្រះដើម្បីទុកជាដំណោះស្រាយ កែតំរូវចំពោះការរំលោភបំពានលើសិទ្ធិរបស់ឌុចដែលបានកើតមាន នេះ?

៨១. នៅពេលដែលតុលាការយោធាសំរេចដកហូតសិទ្ធិរបស់ឌុច ដោយទទួលយកយុត្តាធិការជាក់លាក់មួយ នៅក្រោមច្បាប់ អវតក មាត្រា ៥ ដោយចោទប្រកាន់អំពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះរូបគាត់នោះ គឺមានតំរូវការ"ត្រូវតែទទួលការកាត់សេចក្តី" តាមខ្លឹមសារមាត្រា ២១ របស់ច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលបានផ្តល់សមត្ថកិច្ចយ៉ាងច្បាស់ថា ឌុចមានសិទ្ធិទទួលបានការកាត់

សេចក្តីដែលយុត្តិធម៌ចំពោះការចោទប្រកាន់នោះ និងយ៉ាងហោចណាស់ ក៏រយៈពេលជិត៣ឆ្នាំ ឬ៣ឆ្នាំនៃការឃុំខ្លួនបណ្តោះអាសន្ន បានកំនត់រួចហើយក្នុងច្បាប់ នីតិវិធីព្រហ្មទណ្ឌចំពោះបញ្ហានេះ។ តាមនិយមន័យនៃពាក្យថា"ត្រូវតែទទួលការកាត់សេចក្តី" គឺត្រូវតែលើកលែងការចោទប្រកាន់ ឬនៅក្រោមយុត្តាធិការរបស់អវតក មាត្រា៥នៃច្បាប់អវតក អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគួរមានសំណងសមរម្យ?

៨២. ជាថ្មីម្តងទៀត យោងលើភាសាសាមញ្ញនៃច្បាប់ អវតក ជាតុលាការដែលមានសែស្រឡាយដូចគ្នាទៅនឹងតុលាការយោធាដែលមាននៅក្នុងរចនាសម្ព័ន្ធតុលាការបច្ចុប្បន្ននេះ ដោយមិនគិតពីភាពខុសគ្នាជាក់លាក់ដែលតុលាការនីមួយៗត្រូវមានយុត្តាធិការនិងការគ្រប់គ្រងរដ្ឋបាលរៀបចំដោយច្បាប់ដោយឡែកពីគ្នា និងមិនគិតពីកិច្ចការច្រើនអនេករបស់ អវតក នាពេលបច្ចុប្បន្ននេះ ដែលព្រះរាជាណាចក្រកម្ពុជាត្រូវនាំមកនូវយុត្តិធម៌ជាប្រវត្តិសាស្ត្រ សម្រាប់សម័យដ៏សែនឃោរឃៅ និងជាសម័យដែលពោរពេញដោយភាពភ័យខ្លាច។ នេះបញ្ជាក់យ៉ាងច្បាស់ថា គឺមិនមែនតុលាការយោធាទេដែលមានអំណាចយុត្តាធិការជាដំបូងចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ អវតក នោះទេ។

៨៣. តាមច្បាប់អវតក ទាំងអត្ថបទដំបូងនិងអត្ថបទវិសោធនកម្មរួច និង អត្ថបទចុងក្រោយបានចែងថា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវជាបញ្ហាយុត្តាធិការជាក់លាក់មួយ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អវតក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តុលាការយោធានៅតែទទួលយកយុត្តាធិការនោះ ហើយបានសំរេចដកហូតសិទ្ធិ សេរីភាពនិងសុវត្ថិភាពផ្ទាល់ខ្លួនរបស់ឌុច។ ការដកហូតសេរីភាពនិងការឃុំខ្លួនបណ្តោះអាសន្នរបស់ឌុច ដោយតុលាការយោធា មិនបានគោរពទៅតាមច្បាប់ទេ។ ជាការប្រាកដខ្លាំងណាស់ ឌុចមិនទាន់បានទទួល ការកាត់សេចក្តីចំពោះបទចោទដែលមាន រយៈពេល៥ឆ្នាំកន្លះ និងកំពុងតែបន្ត ទៅទៀត។

៨៤. ជាថ្មីម្តងទៀត សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ទទូចសុំឲ្យអង្គជំនុំជម្រះពិចារណាថាតើរយៈពេល៥ឆ្នាំកន្លះនេះ និងរយៈពេលដែលនឹងបន្តឃុំខ្លួនទៅទៀតនេះ មិនមែនជាការរំលោភបំពានធ្ងន់ធ្ងរជាក់ស្តែងចំពោះសិទ្ធិរបស់ឌុចទេឬ "ដែលត្រូវទទួលបានការវិនិច្ឆ័យទោស" "ធ្វើបណ្តឹងឧបាស្រ័យ" ដើម្បីឲ្យមាន"សវនាការទាន់ពេល" និងដើម្បីឲ្យ "សវនការធ្វើឡើងដោយមិនមានការពន្យាពេលខុសនីតិវិធី"?!

៨៥. ការពិចារណាក្នុងការលើកលែងការចោទប្រកាន់នេះ ឬក៏ផ្អាកយុត្តាធិការរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាដំណោះស្រាយកែតំរូវនោះ គឺពិតជាការលើកលែងមួយមានសារៈសំខាន់ខ្លាំងណាស់ ហើយក្រោមបទដ្ឋាននីតិវិធីច្បាប់ អវតក ការលើកលែងចោទមិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការពិភាក្សា និងពិនិត្យឲ្យបានម៉ត់ចត់នោះ។ ទោះបីជាការវិភាគដែលទូលំទូលាយបានរៀបរាប់ខាងដើមរួចហើយក៏ដោយ ក៏ការបកស្រាយនេះនៅមិនទាន់អាចចាត់ថាមានសមត្ថកិច្ចគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងចំណោទដ៏ធំមួយនេះទេ។ ដូច្នេះ ក្រោមបទដ្ឋានរបស់អវតក វាជាការត្រឹមត្រូវនិងសមរម្យបំផុតដែលអង្គបុរេជំនុំជម្រះស្វែងរក គោលការណ៍ពីវិធាននានាដែលបានបង្កើតក្នុងកំរិតអន្តរជាតិ សម្រាប់ជាជំនួយក្នុងការធ្វើសេចក្តីសម្រេចចិត្តមួយដែលពាក់ព័ន្ធទៅនឹង បញ្ហាសំណង។

**ឃ ការណែនាំពីវិធាននីតិវិធីដែលបង្កើតឡើងក្នុងកំរិតអន្តរជាតិ**

៨៦. ក្នុងពេលនេះ គឺជាចំណុចដ៏សមស្របដែលវិធានបង្កើតឡើងក្នុងកំរិតអន្តរជាតិ ត្រូវដោះស្រាយដោយផ្ទាល់លើបញ្ហាសំណង ដោយត្រូវពិនិត្យរកមើលការណែនាំអំពីបញ្ហានេះ ថាអ្វីអាចជាដំណោះស្រាយសមស្របចំពោះការរំលោភលើសិទ្ធិរបស់ឌុច ដូចដែលបានវិភាគនិងចាត់ថ្នាក់ តាមការបរិយាយខាងលើ។

៨៧. ដើម្បីចាប់ផ្តើមនូវសំណួរនេះ សារណារបស់អ្នកដែលមិនមែនជា ភាគីក្នុងរឿងក្តី សូមស្នើថាភាសាដែលប្រើប្រាស់នៅក្នុងកិច្ចព្រមព្រៀងនិងនៅក្នុងច្បាប់របស់ អវតក អំពី"វិធាននីតិវិធីបង្កើតឡើងក្នុងកំរិតអន្តរជាតិ" ត្រូវតែបកស្រាយថាបាន កើតឡើងយ៉ាងសមហេតុផលនិងត្រឹមត្រូវនៅក្នុងសាលាដំបូង នៅក្នុងវិធាននិងបទដ្ឋានបង្កើត ឡើងដោយយុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្សក្នុងការដោះស្រាយបញ្ហារំលោភបំពានលើICCPR និង/ឬយករឿងក្តី នានាដែលមានលក្ខណៈស្រដៀងគ្នាពីតុលាការអន្តរជាតិឯទៀត ដូចជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ Rwanda (ICTR) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត Yugoslavia (ICTY)។ ទាំងនេះគឺជាស្ថាប័នដែលបង្កើតឡើងដោយអំណាចតុលាការ ដោយមានទម្រង់និងសណ្ឋានអន្តរជាតិពិតៗ ព្រោះស្ថាប័នទាំងនេះបានបង្កើតឡើង ដោយជាក់លាក់តាមរយៈអាជ្ញាធរស្របច្បាប់និងផ្នែករដ្ឋបាលរបស់អង្គការសហប្រជាជាតិ។

00154409



៨៨. ដូចបានលើកឡើងរួចមកហើយ យើងបានលើកពីមូលដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលពួកគាត់ស្ថិតនៅក្នុងការស្វែងរកគោលការណ៍ក្នុងទ្រឹស្តី*ការចាប់ខុស ប៉ុន្តែមិនខុសនីតិវិធីយុត្តាធិការតុលាការក្នុងការឃុំខ្លួនស្របច្បាប់ (male captus, bene detendus)* ដើម្បីកំណត់អំពីបញ្ហាយុត្តាធិការ (male captus, bene detentus) ។ រឿងក្តីទាំងឡាយដែលបានលើកឡើងមកដោយចៅក្រមយោងលើមូលហេតុទាំងនេះ និងដីកាដែលចេញ ដោយតុលាការជាតិជាមួយនឹងការលើកលែងមួយករណីចំពោះរឿងក្តីរបស់ ICTR។[26] រឿងក្តីរបស់តុលាការជាតិទាំងនេះ បានផ្តោតសំខាន់ទៅការរំលោភសិទ្ធិរបស់អធិបតេយ្យភាពរដ្ឋ ច្បាប់នីតិវិធី និងសិទ្ធិមនុស្ស នៅពេលជនសង្ស័យឬជនត្រូវចោទណាម្នាក់ដែលស្ថិតក្នុងដែនដី និងយុត្តាធិការច្បាប់ ផ្សេងពីប្រទេសខ្លួន ឬ ប្រទេសដំបូង (ឬរដ្ឋរបស់សហរដ្ឋអាមេរិច) ត្រូវចាប់និងឃុំខ្លួន ដោយមានការបញ្ជាក់ពីការរំលោភបំពានលើរាងកាយនិងស្មារតី នៅក្នុងប្រទេសមួយផ្សេងទៀត ដើម្បីបញ្ជូននិងនាំខ្លួនយកទៅចំពោះមុខអង្គចៅក្រមនៃតុលាការដែលមានសមត្ថកិច្ចនៅក្នុងប្រទេសដំបូង។

៨៩. ករណីទាំងនេះនិងបញ្ហាទាំងឡាយដែលគេកំពុងជជែក វាផ្ទុយគ្នានឹងមានលក្ខណៈប្លែកពីអ្វីដែលគេយកមកនិយាយនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ បញ្ហាយុត្តាធិការ និងការរំលោភទាំងអស់ដែលចោទប្រកាន់លើនិងឌុចជាអ្នកទទួលរងគឺជាលទ្ធផលនៃការសម្រេចចិត្ត និងការអនុវត្តដោយអាជ្ញាធរតុលាការកម្ពុជា ដែលបង្កើតឡើងក្រោមច្បាប់កម្ពុជាក្នុងសមត្ថកិច្ចដែនដីរបស់កម្ពុជា។ បញ្ហាបានផ្តោតជាមូលដ្ឋានលើឌុច ដែលត្រូវបានចោទនិងឃុំខ្លួនក្រោមច្បាប់ អវតក នៅក្នុងប្រទេសកម្ពុជា និងដោយតុលាការយោធាដែលមានព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត ដោយរង់ចាំការបើកទ្វារ និងការដំណើរការជាផ្លូវការនៃស្ថាប័ន អវតក ហើយការបើកឲ្យដំណើរការនេះ មានការផ្ទេរឌុចទៅ អវតក ដោយចោទប្រកាន់គាត់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បញ្ហាវាមិនពាក់ព័ន្ធនឹងការចាប់ខ្លួន ការឃុំខ្លួននិងការផ្ទេរ (ជាមួយនឹងការបង្ហាញពីការរំលោភលើផ្នែកផ្លូវកាយនិងផ្លូវចិត្ត) ពីយុត្តាធិការពីប្រទេសក្រៅមកកម្ពុជានោះទេ ដូច្នេះគាត់អាចត្រូវគេនាំយកវិនិច្ឆ័យទោសដោយត្រឹមត្រូវនៅចំពោះមុខ អវតក។

---

26 õIn this regard it is worth noting, and as will be more fully developed infra in the more relevant analysis and application of the abuse of process docctrince, it is ICTR jurisprudence that lends the greatest authority for this chamber to decide whether dismissal of the charge, or staying of the ECCC's jurisdiction, is an appropriate remedy.

៩០. និយាយដោយសង្ខេប*ការចាប់ខុស ប៉ុន្តែមិនខុសនីតិវិធីយុត្តាធិការតុលាការក្នុងការឃុំខ្លួនស្រប ច្បាប់* male captus, bene detentus បានផ្ដល់នូវមូលដ្ឋានដែលអាចជជែកតវ៉ាបានខ្លះតាមច្បាប់អន្តរជាតិជាមួយចៅក្រមដែលជាអ្នកធ្វើការសម្រេចចិត្ត ប៉ុន្តែវាមិនសមស្រប ឬអាចអនុវត្តបានចំពោះចៅក្រមក្នុងការស្វែងរកការណែនាំ នៅក្រោមបទដ្ឋានរបស់ អវតក ឡើយ។

៩១. ការពិនិត្យលើសេចក្ដីសំរេចដោយគណៈកម្មាធិការសិទ្ធិមនុស្ស (ជាជំរើសហៅថា "គណៈកម្មាធិការ") និងតុលាការអន្តរជាតិ បានផ្ដល់ឲ្យអំណាចគ្រប់គ្រាន់ដល់អង្គជំនុំជម្រះឲ្យដោះស្រាយបញ្ហានៃការរំលោភសិទ្ធិមនុស្សតាមរយៈបណ្ដឹងឧទ្ធរណ៍នេះ នៅក្រោមបទដ្ឋានអវតក ដែលឌុចបានទទួលអំពើរំលោភនេះដោយផ្ទាល់ក្រោមស្នាដៃនៃសមត្ថកិច្ចកម្ពុជា នៅក្រោមអំណាចតុលាការ និងច្បាប់ជាធរមានរបស់កម្ពុជា។ ការរំលោភសិទ្ធិជាក់ស្ដែងនេះក្រោមច្បាប់នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ បាននិយាយដោយចំៗអំពីសិទ្ធិរបស់ឌុចដែលត្រូវតែបានទទួលការជំនុះជម្រះ បណ្ដឹងឧបាស្រ័យទៅកាន់តុលាការ ទទួលការជំនុំជម្រះតាមពេលវេលាសមស្រប និងត្រូវតែទទួលបានការជំនុំជម្រះដោយមិនមានការពន្យាពេល ក្នុងចំណោមការរំលោភផ្សេងៗទៀតដូចបានរៀបរាប់ខាងលើ។

៩២. ប៉ុន្តែមុននឹងដោះស្រាយបញ្ហាសំណង តាមយុត្តាធិការនៃគណៈកម្មាធិការសិទ្ធិមនុស្ស ក្នុងការបកស្រាយបទបញ្ញត្តិរបស់ ICCPR (កាតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ) អំពីសិទ្ធិទទួលបានការកាត់ទោស ធ្វើបណ្ដឹងឧបាស្រ័យ សវនាការក្នុងរយៈពេលមួយសមស្រប និងសវនការដោយមិនមានការពន្យាពេល បានផ្ដល់ឲ្យយើងនូវវិធានការណ៍ខ្លះដើម្បីវិនិច្ឆ័យ ថាពេលវេលាជាប់ឃុំរបស់ឌុចដោយមិនទាន់ទទួលបានការកាត់សេចក្ដី គឺស្ថិតនៅក្នុងព្រំដែនមួយសមស្រប។

៩៣. ពាក់ព័ន្ធនឹងមាត្រា ៩(៣) ដែលបានចែងថា ជនត្រូវចោទត្រូវទទួលបាននូវសវនាការមួយតាមកាលកំនត់សមស្របនោះ គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថា "អ្វីដែលបង្កើតជាពេលវេលាសមស្រប" គឺជាបញ្ហានៃការវាយតំលៃលើសំណុំរឿងដោយឡែកនីមួយៗ។ គណៈកម្មាធិការសិទ្ធិមនុស្សបានច្រានចោលនូវការខ្វះនូវ"ភាពសមស្របនៃថវិការមិនគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងលើយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ" ដើម្បីបង្ហាញឲ្យបានត្រឹមត្រូវនូវការពន្យាពេលមិនសមស្របដោយរដ្ឋភាគីក្នុងការនាំយកសំណុំរឿងព្រហ្មទណ្ឌមកធ្វើការវិនិច្ឆ័យសេចក្ដី។ គណៈកម្មាធិការសិទ្ធិមនុស្សបានច្រានចោលនូវអង្គហេតុដែលថា ការស៊ើបអង្កេតមានលក្ខណៈទូលាយពេកដែលត្រូវធ្វើដោយ អនុលោមតាមដំណើរការក្ដីដូចបានរៀបចំទុកនោះ ដើម្បីបង្ហាញឲ្យបានត្រឹមត្រូវនូវការពន្យាពេលមិនសមស្របនេះ។

00154411



បញ្ហាដែលទាក់ទងនឹងតំរូវការក្នុងការប្រមូលនូវភស្តុតាងដែលត្រូវបានកំនត់ មិនអាចបញ្ជាក់អំពីការឃុំខ្លួនអស់រយៈពេលដល់ជិត៤ឆ្នាំនោះទេ ហើយករណីនេះត្រូវគណៈកម្មាធិការសិទ្ធិមនុស្សសន្មតថាបានរំលោភនឹងមាត្រា៩(៣)[27]។ ការឃុំខ្លួនដោយមិនមានសវនាការរយៈពេល ៣១ខែ ទៅលើបទចោទដែលត្រូវចោទប្រកាន់ថាជាគណបក្សនយោបាយនៅក្រៅច្បាប់[28] និងការឃុំខ្លួនរយៈពេល៤ឆ្នាំ៤ខែដោយគ្មានសវនាការ នឹងត្រូវចាត់ទុកថាបានរំលោភលើមាត្រា ៩(៣)[29]។

៩៤. តាមយុត្តាធិការរបស់គណៈកម្មាធិការដែលបានដោះស្រាយអំពីបញ្ហាសិទ្ធិក្នុងការទទួលបានសវនាការ“ដោយមិនមានការពន្យាពេលនោះ” ដូចមានក្នុងមាត្រា ១៤(៣)(គ) បានថែងយ៉ាងច្បាស់ថា ស្ថានភាពបញ្ហាសេដ្ឋកិច្ចនៃរដ្ឋភាគីមិនយកមកធ្វើជាលេសក្នុងការមិនអនុវត្តតាមខ្លឹមសារនៃកាតិកាសញ្ញាបានទេ ជាក់ស្តែងដូចជា“សិទ្ធិដែលមានចែងនៅក្នុងកាតិកាសញ្ញានោះ បានបង្កើតនូវបទដ្ឋានអប្បរមាដែលរដ្ឋភាគីទាំងអស់បានយល់ព្រមប្រតិបត្តិតាម។”[30] គណៈកម្មាធិការនេះបានទទួលស្គាល់ការពិតទាំងស្រុងថា តាមមាត្រា៩(៣) និង ១៤(៣) ភាពស្មុគស្មាញនៃសំណុំរឿងមួយត្រូវតែមានការពិចារណាជាដរាប ហើយករណីខ្លះនឹងត្រូវពន្យាពេលដោយមានមូលហេតុត្រឹមត្រូវ។[31] គណៈកម្មាធិការសិទ្ធិមនុស្សបានកំនត់ថា ការពន្យាពេល២៩ខែ[32]និង២ឆ្នាំ ពីថ្ងៃចាប់ខ្លួនរហូតដល់ថ្ងៃសវនាការ គឺជាការរំលោភសិទ្ធិមនុស្ស។[33]

៩៥. សេចក្តីសម្រេចចិត្តទាំងនេះ បានផ្តល់នូវការណែនាំដ៏ល្អសម្រាប់អង្គបុរេជំនុំជម្រះ ដើម្បីវាយតំលៃនូវភាពស្របច្បាប់នៃកាលានុវត្តភាពជុំវិញការឃុំខ្លួនឌុច និងអំពីរយៈពេលនៃការឃុំខ្លួនគាត់ដោយមិនមានសវនាការត្រឹមត្រូវ។ ជាមួយនឹងការដកហូតនូវសិទ្ធិរបស់ឌុច ដែលផ្អែកតាមច្បាប់នីតិវិធីរបស់កម្ពុជា រដ្ឋធម្មនុញ្ញនិងកាតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ICCPR

[27] Communication No. 336/1988, *N. Filastre v. Bolivia* (Views adopted on 5 November 1991), in UN doc. GAOR, A/47/40, p. 306, para. 6.5

[28] Communication No. 314/1988, *P. Chiiko Bwalya v. Zambia* (Views adopted on 14 July 1993), in UN doc.
GAOR, A/48/40 (vol. II), p. 54, para. 6.3

[29] Communication No. 368/1989, *F. Kone v.Senegal* (Views adopted on 21 October 1994), in UN doc. GAOR, A/50/40 (vol. II), p. 8, para. 8.6

[30] Communication No. 390/1990, *B.Lubuto v Zambia* (Views adopted on 31 October 1995), in UN doc. GAOR, A/51/40 (vol. II), p. 14, para. 7.3

[31] Communication No. 336/1988,at p. 306, para. 6.6

[32] Communication No. 564/1993, *J.Leslie v Jamaica* (Views adopted on 31 July 1998), in UN doc. GAOR, A/53/40 (vol. II), p. 28, para. 9.3

[33] Communication No. 672/1995, *C.Smart v Trinidad and Tobago* (Views adopted on 29 July 1998), in UN doc.
GAOR, A/53/40 (vol. II), p. 149, para. 10.2

ជាពិសេសតាមមាត្រា៩(៣)និង១៤(៣)នៃICCPR សេចក្តីសម្រេចចិត្តទាំងនេះរបស់គណៈកម្មាធិការសិទ្ធិមនុស្សបានបង្ហាញថា រយៈពេលឃុំខ្លួនមុនសវនាការរបស់ឌុចនេះអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលទាំងតុលាការយោធា ទាំងអវតក បានចោទដោយមិនបានបញ្ជូនទៅសវនាការនោះ អាចចាត់ទុកថា បានរំលោភនឹងបទដ្ឋានអន្តរជាតិដែលគ្រប់គ្រងលើបញ្ហានេះ។

៩៦. ជាចុងក្រោយ យើងឈានដល់ការរំលោភលើទ្រឹស្តីនៃដំណើរការនីតិវិធី (process doctrine) ដែលអាចត្រូវអនុវត្តចំពោះរឿងក្តី។

៩៧. ការវិភាគលើសំណុំរឿងរបស់ *Jean-Bosco Barayagwiza v The Prosecutor*[34] ដែលយកមកពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR ដែលសំណុំរឿងទាំងនេះបានត្រូវពិភាក្សានិងអនុវត្តយ៉ាងល្អិតល្អន់ពីការរំលោភលើទ្រឹស្តីនៃដំណើរការនេះ ។ បញ្ហានេះត្រូវយកមកធ្វើជាមូលដ្ឋានក្នុងការឈានទៅកំនត់អំពីសំណាងសមស្របមួយ។ ការបើកអង្គជំនុំជម្រះសាលាឧទ្ធរណ៍ចំពោះករណី BaraygwizaI ពិតជាជំទាស់ទៅនឹងអង្គបុរេជំនុំជម្រះនៃអវតក ដើម្បីសម្រេចថាតើត្រូវទាត់ចោល ឬតម្កល់យុត្តាធិការរបស់អវតក អំពីការចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាការសំរេចដ៏ត្រឹមត្រូវចំពោះសំណាង ឬក៏ថាសំណាងនេះ ត្រូវប្រកាសដោយចៅក្រមតាមរយៈដីការបស់ខ្លួន ឬក៏ធ្វើដូចទៅនឹងសំណើរបស់មេធាវីការពារក្តីសម្រាប់ជនជាប់ចោទ ឬអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដទៃទៀត ដែលនេះជារឿងមួយត្រូវគិតគូរ។

៩៨. ការរំលោភលើបទដ្ឋាននៃដំណើរការដែលបានបង្កើតឡើងនោះដែលអាចបង្ហាញឲ្យត្រឹមត្រូវក្នុងការលើកលែងការចោទប្រកាន់ជនត្រូវចោទនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាអ្វីដែលអាចហៅថា ជាបទដ្ឋាននៃ "ការរំលោភដ៏ធ្ងន់ធ្ងរ និងមិនត្រឹមត្រូវ"។

៩៩. ដូចការអនុវត្តផ្ទាល់ទៅនឹងបញ្ហានៅចំពោះមុខអង្គបុរេជំនុំជម្រះ ការរំលោភលើទ្រឹស្តីនៃដំណើរការ ក្នុងការអនុវត្តនូវយុត្តាធិការចំពោះករណីឌុច ដោយយោងទៅលើប្រវត្តិនៃនីតិវិធីនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដែលមានទាំងតុលាការយោធា និងឥឡូវនេះមានទាំងអវតកទៀតផង គឺអាចប៉ះពាល់ដល់ស្មារតីរបស់អវតក ក្នុងការស្វែងរកយុត្តិធម៌ កម្មសិទ្ធនិងសេចក្តីថ្លៃថ្នូរ។

១០០. ចំពោះចំណុចពិសេសនេះ អង្គជំនុំជម្រះឧទ្ធរណ៍ចំពោះករណី Barayagwiza បានបង្ហាញថា:

---

[34] There are two significant cases involving the matter of accused, *Jean-Bosco Barayagwiza,* before the ICTR Appeals Chamber, which will be referred to *infra* as *Barayagwiza I and II – Jean-Bosco*

វាមានសារៈសំខាន់ក្នុងការបញ្ជាក់ថាការរំលោភលើទ្រឹស្តីនៃដំណើរការអាចជាការសំអាងថាជាបញ្ហានៃឆន្ទានុសិទ្ធ។ វាជាដំណើរមួយដែលចៅក្រមអាចប្រានចោលនូវការអនុវត្តនូវយុត្តាធិការរបស់តុលាការចំពោះសំណុំរឿង ដែលយុត្តាធិការនោះវាជាការរំលោភយ៉ាងធ្ងន់ធ្ងរ និងមិនត្រឹមត្រូវលើសិទ្ធរបស់ជនត្រូវចោទ ហើយដែលអាចបណ្តាលឲ្យខូចប្រយោជន៍សេចក្តីថ្លៃថ្នូររបស់តុលាការ។[35]

១០១. ករណីរបស់ Barayagwiza I នេះតុលាការបានពិនិត្យយ៉ាងល្អិតល្អន់លើសំណុំរឿងជា ច្រើនដែលក្នុងនោះការលើកលែងការចោទប្រកាន់ អាចចាត់ទុកជាសំណងមួយដ៏សមរម្យ ចំពោះការរំលោភលើនីតិវិធីដែលអាចត្រូវបានបង្ហាញឲ្យឃើញច្បាស់។ ការព្រួយបារម្ភជាចម្បងរបស់យើង គឺសំខាន់លើការទទួលស្គាល់ថាករណីរបស់Barayagwiza I នេះ តុលាការបានដោះស្រាយបញ្ហាពាក់ព័ន្ធនឹងតួនាទីត្រួតត្រារបស់តុលាការ (ហើយមួយផ្នែកជាមួយរដ្ឋាភិបាល)ប្រទេសកាមីរ៉ូន ជាមួយនឹងតួនាទីរបស់តុលាការ ICTR ក្នុងការនាំខ្លួនជនត្រូវចោទឲ្យមកស្ថិតក្រោមយុត្តាធិការរបស់តុលាការ ICTR ដើម្បីមកប្រឈមមុខនឹងបទចោទប្រកាន់លើខ្លួនគាត់។ ដើម្បីឆ្លើយតបនឹងសំណួរនេះអំពីតួនាទីត្រួតត្រា និងថាតើមានការរំលោភដូចគេចោទប្រកាន់នោះមែនទេ ករណីរបស់ Barayagwiza I ដោយការបំពានលើទ្រឹស្តីនៃដំណើរការនេះ តុលាការបានលើកឡើងថា:

"ជាបឋម ការវិភាគនេះផ្តោតទៅលើការរំលោសិទ្ធរបស់អ្នកប្តឹងឧទ្ធរណ៍ និងមិនពាក់ព័ន្ធជាមួយអង្គភាពដែលត្រូវទទួលខុសត្រូវចំពោះការចោទប្រកាន់អំពីការរំលោភសិទ្ធនោះទេ។ ដូច្នេះ ចំពោះការបំពានលើ *ទ្រឹស្តីនៃដំណើរការ នេះគឺមិនពាក់ព័ន្ធនឹងស្ថាប័នណាមួយដែលត្រូវទទួលខុសត្រូវចំពោះការចោទប្រកាន់អំពីរំលោភបំពានលើសិទ្ធរបស់អ្នកប្តឹងឧទ្ធរណ៍ឡើយ*។"[36](បានបញ្ជាក់បន្ថែម)

១០២. លើសពីនេះទៅទៀត ករណីរបស់ *Barayawigza* តុលាការបានសម្រេចថា នៅពេលដែលរឿងក្តីនោះត្រូវបានគេនាំយកមកនៅចំពោះមុខយុត្តាធិការរបស់ខ្លួន "វាមិនពាក់ព័ន្ធថាតើផ្នែកតូចមួយនៃរយៈពេលទាំងមូលនៃការឃុំខ្លួនបណ្តោះអាសន្នគឺជាភារកិច្ចរបស់តុលាការនោះទេ តែគឺជាតុលាការតែមួយមិនមែនស្ថាប័នណាផ្សេង ដែលជាអ្នកវិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍នេះ"។ ដោយមិនគិតថាតើភាគីណាមួយដែលជាអ្នកទទួលខុសត្រូវនោះទេ តែការសន្និដ្ឋានដែលមិនអាចចៀសផុតនោះ គឺថា"មានការរំលោភសិទ្ធិជាមូលដ្ឋានរបស់អ្នកប្តឹងឧទ្ធរណ៍។"[37]

---

[35] *Barayagwiza I, para. 74*
[36] *Barayagwiza I, para. 73*
[37] *Ibid. at* para. 85

១០៣. ករណី Barayagwiza I តុលាការបានសម្រេចថា ការរំលោភលើដំណើរការដែលមានភស្តុតាងបង្ហាញពីការរំលោភជាបន្តបន្ទាប់ដល់សិទ្ធរបស់ជនត្រូវចោទក្នុងករណីនេះ ជាពិសេសការឃុំខ្លួនគាត់ហួសរយៈពេលកំណត់ដោយគ្មានជូនដំណឹងអំពីបទចោទដល់គាត់ អំពីសិទ្ធិចូលមកបង្ហាញខ្លួននៅចំពោះតុលាការ ការបរាជ័យក្នុងការដោះស្រាយនូវបញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្ត នូវការពិនិត្យនីត្យានុកូលភាពនៃការឃុំឃាំង និងជាចុងក្រោយពាក់ព័ន្ធនឹងការចោទប្រកាន់ ដែលខ្វះខាតនូវការយកចិត្តទុកដាក់ចាត់ការលើសំណុំរឿង គឺតម្រូវឲ្យមានសំណង តាមរយៈការលើកលែងការចោទប្រកាន់ចំពោះជនជាប់ចោទ។[38]

១០៤. ដូច្នេះអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR បានសម្រេចដូចតទៅ:

> បទឧក្រិដ្ឋដែលអ្នកប្ដឹងឧទ្ធរណ៍បានត្រូវចោទប្រកាន់ គឺមានលក្ខណៈធ្ងន់ធ្ងរ។ ប៉ុន្តែក្នុងករណីនេះ សិទ្ធជាមូលដ្ឋានរបស់អ្នកប្ដឹងឧទ្ធរណ៍បានត្រូវរំលោភបំពានជាបន្តបន្ទាប់។ អ្វីដែលកាន់តែអាក្រក់ជាងនេះទៅទៀតនោះ គឺការបរាជ័យរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់លើរឿងក្ដីនេះ ដោយសារតែការធ្វេសប្រហែស។ យើងរកឃើញថាអំពើនេះមានលក្ខណៈធ្ងន់ធ្ងរពាក់ព័ន្ធទៅនឹងការរំលោភបំពានមួយចំនួន សូមសន្និដ្ឋានថាមានដោះស្រាយសម្រាប់សំណងតែមួយគត់ចំពោះការមិនបានចោទប្រកាន់និងការបដិសេធអំពីសិទ្ធរបស់គាត់នោះ គឺត្រូវដោះលែង និងលើកលែងចោទប្រកាន់ចំពោះរូបគាត់។[39]

១០៥. បញ្ហាពាក់ព័ន្ធនឹងភាពមិនត្រឹមត្រូវ និងការធ្វេសប្រហែសចំពោះការចោទប្រកាន់នោះបានបង្កបញ្ហាធ្ងន់ធ្ងរដល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ចំពោះករណី Barayagwiza I។ បន្ទាប់ពីមានសេចក្ដីសម្រេចចិត្តលើកទីមួយមក យោងទៅលើបណ្ដឹងសើរើ ការិយាល័យអាជ្ញាការមានឱកាសបង្ហាញភស្តុតាងនិងអង្គហេតុថ្មី ទៅឲ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែលខ្លួនមិនទាន់បានបង្ហាញនៅដំណាក់កាលទីដំបូង ដើម្បីលុបបំបាត់បញ្ហានៃការធ្វេសប្រហែស និងការប្រព្រឹត្តមិនត្រឹមត្រូវ។ សវនាការលើកទីពីរនេះនៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍ អាចហៅថាជាករណី Barayagwiza II។ បន្ទាប់ពីបានពិនិត្យមើលសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់អាជ្ញាការចំពោះ Barayagwiza II អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានត្រឡប់ទៅដោះស្រាយករណីរបស់ Barayagwiza I វិញ ហើយបានសម្រេចថា សេចក្ដីសន្និដ្ឋានចោទប្រកាន់ជាថ្មីបានបង្ហាញថា អាជ្ញាការមិនមានកំហុសធ្ងន់ធ្ងរ

[38] *Ibid. at* para. 102-106

[39] *Ibid. at* para. 106.

លើការចោទប្រកាន់ចំពោះករណីនេះទេ។ ដូច្នេះអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ការលើកលែងចោទប្រកាន់និងដោះលែងអ្នកប្តឹងឧទ្ធរណ៍នោះ គឺមិនសមាមាត្រទៅនឹងដំណោះស្រាយចំពោះការរំលោភដ៏ធ្ងន់ធ្ងរលើសិទ្ធិរបស់គាត់បើប្រៀបធៀបនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ចំពោះករណី Barayagwiza II បានបញ្ជាក់អំពីការរំលោភធ្ងន់ធ្ងរលើសិទ្ធិរបស់អ្នកប្តឹងឧទ្ធរណ៍នោះ ហើយសម្រេចថាត្រូវមានសំណងសមស្របមួយដែលអាចជាសំណងជាប្រាក់កាស ឬជាការបន្ថយទោសទណ្ឌក្នុងករណីដែលអ្នកប្តឹងឧទ្ធរណ៍នោះត្រូវបានរកឃើញថាមានកំហុសក្នុងពេលសវនាការ។[40]

១០៦. បញ្ហានៃតុលាការអន្តរជាតិក្នុងការច្រានចោលមិនទទួលយកយុត្តាធិការចំពោះជនជាប់ចោទបានត្រូវគេលើកឡើងនិងសាកល្បងនៅក្នុងតុលាការICTY ជាពិសេសចំពោះសំណុំរឿង *Prosecutor v. Dragan Nikolic*។ ចំពោះករណី *Nikolic* តុលាការICTYបានសួរថា"ប្រសិនបើមាន តើក្នុងកាលៈទេសៈបែបណាដែលតុលាការអន្តរជាតិគួរតែបដិសេធនូវការអនុវត្តយុត្តាធិការរបស់ខ្លួន ពីព្រោះជនជាប់ចោទបានត្រូវនាំខ្លួនមកចំពោះមុខតុលាការខ្លួន តាមរយៈកាយវិការមួយដែលមានការរំលោភលើអធិបតេយ្យភាពរបស់រដ្ឋ និងសិទ្ធមនុស្ស។"[41] បញ្ហាធំមួយចំពោះការវិភាគរបស់ ICTY ចំពោះករណី *Nikolic* នោះគឺការរំលោភលើអធិបតេយ្យភាពរដ្ឋ ដែលជាបញ្ហាមួយមិនធ្លាប់ជួបប្រទះពីមុន។ ការវិភាគគឺខិតជិតនៅនឹងបញ្ហាដែលបានលើកឡើងនៅក្រោមទ្រឹស្តីនៃ *ការចាប់ខុស ប៉ុន្តែមិនខុសនីតិវិធីយុត្តាធិការតុលាការក្នុងការឃុំខ្លួនស្របច្បាប់*(male captus, bene detentus) ដែលចៅក្រមពិនិត្យមើលលើមូលដ្ឋានរបស់ខ្លួនដូចបានបញ្ជាក់ពីខាងដើម។ ដូចដែលសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីបាននិយាយពីខាងដើមមកថា នេះមិនមែនជាបញ្ហាមួយចំពោះមុខអង្គជំនុំជម្រះនោះទេ។ ក្នុងការដោះស្រាយថាតើ ICTY ពិនិត្យមើលយ៉ាងដូចម្តេចលើការរំលោភសិទ្ធិមនុស្ស ករណី *Nikolic* តុលាការបានផ្តោតជាខ្លាំងទៅលើថាតើសិទ្ធរបស់ជនជាប់ចោទត្រូវរងការរំលោភបែបអមនុស្សធម៌ ឃោរឃៅ ឬក៏ការធ្វើទារុណកម្ម ឬអាប់អោនកិត្តិយស ឧទាហរណ៍ដូចជា ការរំលោភធ្ងន់ធ្ងរលើស្មារតី និងរាងកាយ នៅពេលណាក៏ដោយចំពោះមុខអង្គជំនុំជម្រះ គឺមានការស្នើសុំឱ្យទទួលយកយុត្តាធិការលើរឿងក្តីរបស់ជនជាប់ចោទ។ តុលាការគិតឃើញថាការរំលោភបែបនេះបង្ហាញនូវការរំលោភក្នុងលក្ខណៈធ្ងន់ធ្ងរ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ចំពោះករណី *Nikolic* មិនបានច្រាន

---

[40] *Barayagwiza II*, paras. 74-75

[41] *Prosecutor v. Dragan Nikolic*, ICTY, Appeals Chamber decision of 5 June 2003, para. 18.

ចោលយុត្តាធិការទេ ពីព្រោះអង្គជំនុំជម្រះនេះបានរកឃើញថា "ការប្រព្រឹត្តលើអ្នកដែលប្តឹងឧទ្ធរណ៍មិនមានលក្ខណៈធ្ងន់ធ្ងរទេ"។[42]

១០៧. ដីការបស់ចៅក្រមស៊ើបអង្កេតបង្ហាញថា ពួកគាត់មានការយកចិត្តទុកដាក់ចំពោះការអនុវត្តការ រំលោភលើទ្រឹស្តីនៃដំណើរការ--ថាតើមានការរំលោភលើស្មារតីនិងរាងកាយធ្ងន់ធ្ងរឬទេ លើជនជាប់ចោទ មុនពេលនាំយកមកនៅចំពោះមុខអវតក-- ក្នុងការសម្រេចថាតើត្រូវទទួលយក ឬបដិសេធនូវយុត្តាធិការនៃសំណុំរឿងរបស់ឌុច។ ប្រហែលជាការចាប់ខ្លួនឌុច ហើយឃុំខ្លួនគាត់នៅតុលាការយោធា អាចត្រូវបានពិចារណាបានថាធ្វើដោយគ្មានការរំលោភធ្ងន់ធ្ងរលើរាងកាយនិងស្មារតីទេ ទោះបីជាសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី មិនទាន់បានឃើញអង្គហេតុ ឬភស្តុតាងដែលបានដើម្បីយកមកបញ្ជាក់ ឬផ្តល់ជាគំនិតចំពោះប្រធានបទនេះក៏ដោយ។

១០៨. តាមបទដ្ឋានរបស់អវតក ការស្វែងរកការណែនាំពេលនេះពីវិធាននានាដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ ដើម្បីជួយដល់អង្គបុរេជំនុំជម្រះក្នុងការធ្វើការសម្រេចចិត្ត និងចេញសាលក្រមអំពីបញ្ហាសំណង។

១០៩. សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី បានបញ្ជូននូវគោលការណ៍ដែលទទួលបានពីសំណុំរឿងដ៏ច្រើនរបស់កម្មាធិការសិទ្ធមនុស្ស ព្រមទាំងចំណុចសំខាន់ៗជាច្រើនពី ICTR ចំពោះករណី Barayagwiza ដែលបានបង្ហាញពីខាងដើមទាក់ទងនឹងការរំលោភលើទ្រឹស្តីនៃដំណើរការ ដែលជាការអនុវត្តដោយផ្ទាល់ និងជាចំណុចគួរជឿទុកចិត្តលើការវាយតម្លៃនិងសម្រេចលើបញ្ហាយុត្តាធិការនៃសំណុំរឿងនេះ។ ចំនួននិងប្រភេទនៃការរំលោភលើសិទ្ធនេះក្រោមច្បាប់នីតិវិធីរបស់កម្ពុជា និងសិទ្ធជាមូលដ្ឋានផ្អែកតាមរដ្ឋធម្មនុញ្ញនិងច្បាប់សិទ្ធមនុស្សអន្តរជាតិគឺមិនអាចមិនយកចិត្តទុកដាក់ ឬមើលរំលងបានទេ។ ដូចករណី Barayagwiza I គឺបង្ហាញឲ្យឃើញពីចំនួននិងប្រភេទនៃការរំលោភដែលបញ្ហានេះពិបាកថាគេចផុតពីការធ្វើសន្និដ្ឋានថាមានការរំលោភធ្ងន់ធ្ងរពិតប្រាកដ។

ដែលរបៀបនៃការរំលោភនេះ គឺមានការពិបាកណាស់ក្នុងការមិនធ្វើការសន្និដ្ឋានថាការរំលោភនេះគឺមានលក្ខណៈធ្ងន់ធ្ងរខ្លាំង។ ការពិចារណាចំពោះករណី Barayagwiza នៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍គឺពាក់ព័ន្ធទៅការរំលោភដែលបានកើតឡើងនៅក្នុងតុលាការយោធារបស់កម្ពុជា ពីព្រោះករណីនេះកើតឡើងមុនពេលសំណុំរឿងនេះបញ្ជូនមកដល់អវតក ប៉ុន្តែឥឡូវនេះគឺជាសមត្ថកិច្ច អវតកដែលវិនិច្ឆ័យលើការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ដូច្នេះ អង្គបុរេជំនុំជម្រះនៃអវតក មាន

[42] *Nikolic, at* para. 31.

ភារៈកិច្ចធ្ងន់ធ្ងរក្នុងការកំណត់ថាតើការរំលោភលើសិទ្ធរបស់ឌុចនោះគឺជាបញ្ហាធ្ងន់ធ្ងរក្នុងការអនុវត្តយុត្តាធិការមកលើឌុច ដែលអាចនឹងបណ្តាលឲ្យអាប់អោនដល់កេរ្តិ៍ឈ្មោះរបស់តុលាការនេះ ក្នុងការបំពេញភារកិច្ចដ៏សំខាន់ក្នុងការស្វែងរកយុត្តិធម៌។

១១០. ពាក់ព័ន្ធនឹងបញ្ហានៃការធ្វេសប្រហែសនិងការប្រព្រឹត្តមិនត្រឹមត្រូវនៃការចោទប្រកាន់នោះ វាប៉ះពាល់ដល់លទ្ធផលនៃសំណុំរឿងរបស់ Barayagwiza។ បញ្ហានេះគឺត្រូវតែមានការទទួលស្គាល់ថាច្បាប់ អវតកត្រូវបានចូលជាធរមាន ព្រះរាជអាជ្ញានៃតុលាការយោធាកម្ពុជានិងចៅក្រមស៊ើបអង្កេតបានសម្រេចអនុវត្តនូវយុត្តាធិការចំពោះឌុច តាមច្បាប់អវតក អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះបីជាដឹងរួចទៅហើយថាមានតែអវតកដែលជាតុលាការមួយស្ថិតក្នុងក្របខ័ណ្ឌប្រព័ន្ធតុលាការកម្ពុជាទេ ទើបមានយុត្តាធិការលើបទឧក្រិដ្ឋដែលស្ថិតក្រោមច្បាប់អវតកនោះ។ ចំណុចនេះហាក់ដូចជាបំពានដល់គំនិតជាមូលដ្ឋានចំពោះតុលាការនេះ។

១១១. ពេលដែលតុលាការយោធាបានប្រើអំណាចរបស់ខ្លួនប្រព្រឹត្តលើឌុច ផ្អែកតាមច្បាប់អវតកនោះ តុលាការនេះបានអនុវត្តតាមច្បាប់នីតិវិធីរបស់កម្ពុជានិងសិទ្ធដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងICCPR ។ លើសពីនេះទៅទៀត នៅពេលដែលច្បាប់អវតកត្រូវបានអនុម័ត ហើយឌុចត្រូវបានចោទប្រកាន់នៅឯតុលាការយោធា គឺជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការសហការជាមួយអង្គការសហប្រជាជាតិ ដែលជាភាគីទទួលខុសត្រូវក្នុងការបង្កើត អវតកឲ្យដំណើរការប្រកបដោយប្រសិទ្ធិភាពនិងទាន់ពេលវេលា ហើយនិងត្រូវបញ្ជាក់ ថាឌុចត្រូវតែមានសិទ្ធទទួលបាននូវវិនិច្ឆ័យទោស សិទ្ធក្នុងធ្វើបណ្តឹងឧបាស្រ័យ និង សវនាការតាមពេលវេលាមួយសមស្រប ដោយមិនមានការពន្យាពេល។

១១២. ប្រសិនបើមានការធ្វេសប្រហែសឬការប្រព្រឹត្តមិនត្រឹមត្រូវ ភាគីកម្ពុជា និងអង្គការសហប្រជាជាតិត្រូវតែចូលរួមទទួលខុសត្រូវ ក្នុងការបង្កើតនិងដាក់ឲ្យ អវតក ដំណើរការដើម្បីទទួលយកបញ្ហាដែលមិនគួរឲ្យកើតមានជាយូរមកហើយនេះមកដោះស្រាយ។ បញ្ហានេះត្រូវការពេលវេលាច្រើន និងជួនកាលជាដំណើរការដ៏តានតឹង ដើម្បីដោះស្រាយបញ្ហាសិទ្ធិជាមូលដ្ឋានរបស់ឌុចដែលគឺជាសិទ្ធិត្រូវតែគោរពនិងលើកតម្កើនដោយតុលាការទាំងអស់នៅក្នុងប្រព័ន្ធតុលាការជាតិកម្ពុជា រួមទាំងអវតក ផងដែរនៅពេលឥឡូវនេះ និងគឺជាសិទ្ធិដែលបានត្រូវរំលោភនិងប្រហែលជារឿងក្តីដែលអវតក កំពុងតែដំណើរការ ហើយដែលត្រូវតែបដិសេធមិនទទួលយកយុត្តាធិការលើរឿងក្តីនេះ។

១១៣. ការរំលោភសិទ្ធខុចដោយអនុវត្តតាមច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា រដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធមនុស្សអន្តរជាតិ គឺមានច្រើនដូចបានរៀបរាប់ពីខាងដើមរួចមកហើយ។ ដូចករណីអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ករណី *Barayagwiza* និងករណី *Nikolic* ដែលយើងបានយល់យ៉ាងច្បាស់នោះគឺ"តុល្យភាពដ៏ត្រឹមត្រូវមួយ គឺត្រូវតែរក្សាការពាររវាងសិទ្ធជាមូលដ្ឋានរបស់ជនជាប់ចោទ និងចំណាប់អារម្មណ៍ដ៏ខ្លាំងរបស់របស់សហគមន៍អន្តរជាតិ ក្នុងការកាត់សេចក្តីជនត្រូវចោទអំពីការរំលោភដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។"[43]

១១៤. សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី គោរពទាំងស្រុងចំពោះតម្រូវការដ៏សមហេតុផលរបស់អង្គបុរេជំនុំជម្រះរបស់អវតក ក្នុងការស្វែងរកនូវតុល្យភាពមួយដ៏ត្រឹមត្រូវក្នុងការសម្រេចសេចក្តីរបស់ខ្លួន។

## V <u>សំណូមពរចំពោះសាលក្រម</u>

១១៥. អង្គបុរេជំនុំជម្រះ ត្រូវចេញនូវដីកាមួយដែលអាចចាត់ទុកជាការចាប់ផ្តើមនិងជាតម្រូវការដ៏សំខាន់នៃដំណើរការក្នុងការធ្វើសេចក្តីសម្រេចចិត្តនិងចេញសាលក្រម ដើម្បីបង្កើតជាបទដ្ឋានរបស់អវតក ដែលសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះទាំងអស់របស់អវតក ត្រូវតែគោរពប្រតិបត្តិតាម។ នេះគឺជាក្របខ័ណ្ឌមួយជាក់ស្តែងនិងច្បាស់លាស់ដើម្បីឈានដល់ការសម្រេចចិត្តដូចមានចែងក្នុងវិធានផ្ទៃក្នុង កិច្ចព្រមព្រៀង និងច្បាប់បង្កើតអវតកដែលត្រូវតែគោរព និងអនុវត្តតាមឱ្យបានពេញលេញ។

១១៦. ក្នុងការបង្កើតនិងអនុវត្តឱ្យបានត្រឹមត្រូវនូវបទដ្ឋានអវតក សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី បានដាក់ជូននូវអំណះអំណាងផ្លូវច្បាប់ដ៏គ្រប់គ្រាន់និងពេញលេញដល់អង្គបុរេជំនុំជម្រះ ដើម្បីធ្វើការសម្រេចចិត្តនិងចេញសាលក្រមតម្កល់យុត្តាធិការរបស់អវតកចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលអនុវត្តតាមច្បាប់អវតក មាត្រា៥ ចោទអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើរូបឌុច។

១១៧. សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី សូមទុកបញ្ហានេះជូនទៅមេធាវីការពារក្តី ឬអ្នកធ្វើសារណាដទៃទៀត ឱ្យដាក់សំណើដទៃទៀតសម្រាប់ជាជំនួយដល់អង្គបុរេជំនុំជម្រះ ក្នុងការពិនិត្យមើលលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន។

---

[43] *Nikolic, at* para. 30.

VI <u>សន្និដ្ឋាន</u>

១១៨. ទោះបីជាអង្គបុរេជំនុំជម្រះធ្វើការសម្រេចចិត្តនិងចេញសាលក្រមចុងក្រោយចំពោះបញ្ហានេះយ៉ាងម៉េចក៏ដោយ អ្នកដែលមិនមែនជាភាគីនៃរឿងក្តី មានជំនឿទុកចិត្តថា សេចក្តីសម្រេចចិត្តនិងសាលក្រមទាំងនេះ នឹងត្រូវធ្វើឡើងក្នុងលក្ខណៈមួយសមស្របទៅបទដ្ឋានអន្តរជាតិក្នុងការធ្វើសវនាការប្រកបដោយយុត្តិធម៌ សមត្ថភាព ឯករាជ្យនិងភាពអនាគតដែលគោលការណ៍ទាំងនេះ ត្រូវមានសម្រាប់តុលាការទាំងអស់របស់កម្ពុជារួមទាំង អវតក ផងដែរ។

១១៩. អ្នកដែលមិនមែនជាភាគីនៃរឿងក្តី មានកិត្តិយសសូមយកឱកាសនេះដាក់ជូននូវសេចក្តីសន្និដ្ឋាននេះ ហើយសង្ឃឹមថាបានជួយដល់អង្គបុរេជំនុំជម្រះនៃអវតក ក្នុងការឈានទៅធ្វើការសម្រេចចិត្ត និងចេញសាលក្រមចំពោះព្រឹត្តិការណ៍ដ៏សំខាន់ និងជាប្រវត្តិសាស្ត្រនេះ។

ភ្នំពេញ ថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០០៧

ហត្ថលេខា

លោក Jeffrey M. KAHAN